# ជំនួយបច្ចេកទេសនៅប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩៩៨-២០០៣ [1]

## ១. សេចក្តីផ្តើម

១-ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសជាច្រើន ដែលបានទទួលជំនួយបច្ចេកទេសពីមូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងរយៈពេលជាងមួយទសវត្សមកនេះ ។ ចន្លោះឆ្នាំ ១៩៩៨ ដល់ឆ្នាំ ២០០៣ ប្រទេសកម្ពុជាទទួលបាននូវជំនួយបច្ចេកទេសជាមធ្យមជាង ៤នាក់X១ឆ្នាំ ក្នុងមួយឆ្នាំៗ ហើយជាប្រទេសដែលទទួលបានប្រយោជន៍ច្រើនជាងគេបំផុតក្នុងចំណោមបណ្តាប្រទេសនានាក្នុងឆ្នាំ ២០០៣ ។ ម៉្យាងទៀត ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេស ពីរ ឬ បីដែលត្រូវបានផ្តល់ជំនួយបច្ចេកទេស ក្រោមវិសាលភាពនៃកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស (TCAP) រវាងឆ្នាំ ២០០១ និង ២០០៣ ។ មាតិកានៃកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេសកម្ពុជាត្រូវបានរៀបចំរួមគ្នា ដោយអាជ្ញាធរម្ចាស់ជំនួយដ៏ទៃទៀត និង មូលនិធិរូបិយវត្ថុអន្តរជាតិ ដោយបង្កើតបានជាកម្មវិធីទូលំទូលាយមួយសំរាប់ជំនួយបច្ចេកទេស គ្របដណ្តប់វិស័យគន្លឹះសំខាន់ៗ ពាក់ព័ន្ធទៅនឹងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច មានជាអាទិ៍ នៅផ្នែកសារពើពន្ធ និង ធនាគារ ព្រមទាំងផ្នែកស្ថិតិ ។ ជាលទ្ធផល ប្រទេសកម្ពុជាផ្តល់នូវឱកាសដ៏ល្អមួយ ដើម្បីបង្ហាញមេរៀនខ្លះអំពីកត្តាដែលជះឥទ្ធិពលដល់ប្រសិទ្ធិភាព និង ភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេស ។ ជាពិសេស មានសំនួរពីរដែលករណីសិក្សានឹងផ្តោតការយកចិត្តទុកដាក់ : តើអ្វីខ្លះមានភាពប្រសើរឡើងជាសក្តានុពល (ប្រសិនបើមាន) តាមមធ្យោបាយដែលមូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់ជំនួយបច្ចេកទេស? និង តើស្ថានភាពជាក់លាក់របស់ប្រទេសអ្វីខ្លះដែលធ្វើអោយជំនួយបច្ចេកទេសអាចមានឥទ្ធិពលច្រើន? ។ ជាលទ្ធផល ករណីសិក្សានេះត្រូវបានរៀបចំជាបីផ្នែកធំៗ ។ ទីមួយ គឺផ្នែកសាវតាដែលនឹងរៀបរាប់ដោយសង្ខេបនូវរាល់សកម្មភាពជំនួយបច្ចេកទេសចំបងៗ និង ធ្វើការវាយតំលៃជាទូទៅពីភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេសទាំងនោះ ។ ការរៀបរាប់នេះ ផ្តោតតែទៅលើកម្មវិធីសហប្រតិបត្តិការជំនួយការបច្ចេកទេសឆ្នាំ ២០០១-២០០៣ ពីព្រោះថាជំនួយបច្ចេកទេសដែលបានទទួលមានច្រើន ក្នុងរយៈពេលនេះ ព្រមទាំងមានភស្តុតាងផងដែរ ។ ផ្នែកទីពីរនឹងស្វែងយល់ពីកត្តាជាក់លាក់នីមួយៗរបស់ប្រទេស ដែលអាចនឹងមានឥទ្ធិពលដល់ជំនួយការបច្ចេកទេស ។ ហើយផ្នែកទីបី នឹងធ្វើការវិភាគពីមធ្យោបាយដែលអាចអោយមូលនិធិរូបិយវត្ថុអន្តរជាតិ ធ្វើការកែលំអរលើការបែងចែកជំនួយបច្ចេកទេស ដើម្បីសំរេចជោគជ័យគ្រប់ដំណាក់កាលដែលខ្លួនពាក់ព័ន្ធ ។

២ សូមបញ្ជាក់ថា ទោះបីជារបាយការណ៍នេះនឹងផ្តោតជាសំខាន់ទៅលើទៅលើទិដ្ឋភាពទាំងឡាយដែលអាចធ្វើអោយប្រសើរឡើងក៏ដោយក៏នៅក្នុងប្រទេសកម្ពុជា មានការទទួលស្គាល់ជាសាកលភាគច្រើនពីគុណភាព និងភាពពាក់ព័ន្ធនៃជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ អាជ្ញាធរប្រទេសកម្ពុជា ក៏ដូចជាម្ចាស់ជំនួយអន្តរជាតិនានាបានសសើរម្តងហើយម្តងទៀតពីសមត្ថភាពបច្ចេកទេស ដ៏ល្អប្រសើររបស់ជំនាញការភាគច្រើននៅក្រោមជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ហើយព្រមទាំងសង្កត់ធ្ងន់ពីភាពពាក់ព័ន្ធដើម្បីរួមចំណែកក្នុងការដោះស្រាយ

---

[1] ផ្អែកលើកិច្ចសម្ភាសន៍ដែលដឹកនាំដោយ IEO ជាមួយមន្ត្រីរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយបច្ចេកទេសពហុភាគី និង ទ្វេភាគី នៅទីក្រុងភ្នំពេញនៅកម្ពុជា នៅចន្លោះថ្ងៃទី ៨-១៨ មិថុនា ឆ្នាំ ២០០៤ និង ធ្វើការសម្ភាសន៍ជាមួយមន្ត្រីធនាគារពិភពលោក និងបុគ្គលិកមូលនិធិរូបិយវត្ថុអន្តរជាតិនៅទីក្រុងវ៉ាស៊ីនតោន រួមទាំង អនុស្សរណៈ និង ទំនាក់ទំនងផ្ទៃក្នុងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ព្រមទាំងរបាយការណ៍ធនាគារពិភពលោក និងមូលនិធិរូបិយវត្ថុអន្តរជាតិ ។

បញ្ហាកង្វះសមត្ថភាពនៅកម្ពុជា ។ នៅក្នុងន័យនេះហើយដែលការធ្វើអត្ថាធិប្បាយ និង ការសន្និដ្ឋាននីមួយត្រូវលើកយកមកពិចារណា ។

## ២. សាវតា

៣-អស់រយៈពេល ១០ ឆ្នាំ បន្ទាប់ពីចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងឆ្នាំ ១៩៩១មក កម្ពុជានៅតែតទល់ទៅនឹងបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ចធំៗជាច្រើន ។ ចំណូលពន្ធនៅមានកំរិតទាប ប្រព័ន្ធធនាគារមិនរឹងមាំ ហើយកំណែទំរង់មូលដ្ឋានគ្រឹះនៃស៊ីវិលនិងរដ្ឋបាល ជាការចាំបាច់ដើម្បីកែលំអរអភិបាលកិច្ច [2] ។ នៅក្នុងន័យនេះ ជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ភាគច្រើនត្រូវបានផ្តល់ទៅអោយវិស័យ ៤ នៅក្រោមកម្មវិធីសហប្រតិបត្តិការជំនួយការបច្ចេកទេស : កំណែទំរង់សារពើពន្ធ កំណែទំរង់ប្រព័ន្ធធនាគារ ស្ថិតិ និង ប្រព័ន្ធនីតិសាស្ត្រ [3] ។ ក្នុងវិស័យទាំងអស់នេះ កម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស បានគូសព្រាងសកម្មភាពជំនួយបច្ចេកទេសជាក់លាក់មួយចំនួនសំរាប់ជំនាញការ និង លទ្ធផលសង្ឃឹមនឹងទទួលបានពីពួកគេ ។ ម៉្យាងវិញទៀត កម្មវិធីសហប្រតិបត្តិការ បានកំណត់និយមន័យនៃការបែងចែកជំនួយបច្ចេកទេសជាគំរូដូចជា « រយៈពេលវែង រយៈពេលខ្លី ការផ្ទេរចំណេះដឹង តាមការងារ » ទៅតាមសកម្មភាពនីមួយៗព្រមទាំងរយៈពេល និង ពេលវេលានៃអាណត្តិរបស់ពួកគេ។ ជាលទ្ធផល លក្ខខណ្ឌការងារ (TORs) នៃក្រុមជំនាញការភាគច្រើន ឆ្លុះបញ្ចាំងជាសារវន្តពីគោលការណ៍ទាំងអស់នេះ។

៤-ក្នុងវិស័យសារពើពន្ធ ជំនួយបច្ចេកទេសសំដៅទៅរក ១) ពង្រឹងគោលនយោបាយ និងរដ្ឋបាលពន្ធដាររួមទាំងប្រភពធនធានមនុស្ស និងការកែលំអរប្រព័ន្ធពន្ធដារ ២) ពង្រឹងរដ្ឋបាលពន្ធគយ ដើម្បីទទួលបានផលជាអតិបរមា ពីអធិការកិច្ចមុនពេលផ្ទុកដើម្បីបង្កើនសមត្ថភាពអនុវត្តន៍ច្បាប់ និង ដើម្បីធ្វើអោយទំនើបនីយកម្ម និង បញ្ច្រាបនីតិវិធីទាំងឡាយ និង ៣) ពង្រឹងការគ្រប់គ្រងថវិកាដើម្បីកែលំអរគុណភាពនៃការរៀបចំ និងប្រតិបត្តិថវិកា ជាមួយនឹងការបង្កើតអោយមាន និង អនុវត្តអោយមានប្រសិទ្ធិភាពនូវសវនកម្មផ្ទៃក្នុង និងពីខាងក្រៅ។ មានជំនាញការប្រចាំរយៈពេលវែង៣ នាក់ ដែលមានជំនាញលើផ្នែកគ្រប់គ្រងថវិកា រដ្ឋបាលគយ និង រដ្ឋបាលពន្ធដារ បានធ្វើការដើម្បីសំរេចអោយបាននូវគោលបំណងទាំងនេះ ។ ជំនាញការទាំងបីនាក់នេះគិតទៅជាងពាក់កណ្តាលនៃជំនួយបច្ចេកទេសសរុប ដែលបានផ្តល់អោយក្រោមកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស ។

៥-គោលបំណងទូទៅនៃជំនួយបច្ចេកទេសក្នុងផ្នែកកំណែទំរង់ធនាគារ គឺដើម្បីជួយបង្កើតនូវប្រព័ន្ធធនាគារមួយ ដែលមានភាពរឹងមាំ និងប្រសិទ្ធិភាព តាមរយៈការផ្តល់អាជ្ញាប័ណ្ណអោយធនាគារឡើងវិញ ការពង្រឹងបទបញ្ញត្តិ និង ការកែលំអរការគ្រប់គ្រងធនាគារ ។ ជំនួយបច្ចេកទេសលើស្ថិតិសេដ្ឋកិច្ច គឺសំដៅលើការពង្រឹងសមត្ថភាព ក្នុងការចងក្រងស្ថិតិ សំរាប់ធ្វើគោលនយោបាយសេដ្ឋកិច្ច និង ធ្វើផែនការវិនិយោគឯកជន តាមរយៈការកែលំអរគណនីជាតិ ទិន្នន័យពីថ្លៃ ពាណិជ្ជកម្មអន្តរជាតិ និង ជញ្ជីងទូទាត់ ហិរញ្ញវត្ថុរដ្ឋាភិបាល និង ស្ថិតិអំពីរូបិយវត្ថុ និង ធនាគារ ។ គោលបំណងនៃជំនួយបច្ចេកទេសក្នុងវិស័យច្បាប់ គឺការលំអរឡើងវិញនូវក្របខ័ណ្ឌច្បាប់ក្នុងវិស័យហិរញ្ញវត្ថុ ។ ចំនួន

[2] IMF, (Cambodia Article IV) (2000)

[3] សំរាប់កិច្ចពិភាក្សាល្អិតល្អន់ជាងនេះពីគោលបំណងនៃកម្មវិធីសហប្រតិបត្តិការជំនួយការបច្ចេកទេស សូមអាន UNDP «កម្មវិធីនៃរដ្ឋាភិបាលកម្ពុជា : ឯកសារសំរាប់គាំទ្រកម្មវិធី» (២០០១) ។

ភាគច្រើនបំផុតនៃជំនួយបច្ចេកទេសត្រូវបានផ្តល់ដោយ FAD និងផ្តល់ជាបន្តបន្ទាប់ដោយ MFD, STA និង LEG ។ ជំនាញការប្រចាំរយៈពេលវែង គឺជាយន្តការមួយដ៏សំខាន់ក្នុងការផ្តល់នូវជំនួយបច្ចេកទេស ។ ជំនួយបច្ចេកទេសផ្នែកច្បាប់ផ្តល់អោយភាគច្រើនតាមរយៈបេសកកម្មរយៈពេលខ្លីៗ (តារាងទី ១) ។

**តារាង ១: ជំនួយបច្ចេកទេសនៅកម្ពុជា**
**(គិតជាចំនួនថ្ងៃសរុប) ១/**

| នាយកដ្ឋាន | ការពិពណ៌នា | ឆ្នាំ ១៩៩៨ | ឆ្នាំ ១៩៩៩ | ឆ្នាំ ២០០០ | ឆ្នាំ ២០០១ | ឆ្នាំ ២០០២ | ឆ្នាំ ២០០៣ |
|---|---|---|---|---|---|---|---|
| MFD | គណនេយ្យ | ៤២ | - | - | - | - | ១០ |
| | ការកែតម្រូវរចនាសម្ព័ន្ធ និងការគ្រប់គ្រងធនាគារ | ២២ | - | - | ១៧២ | ២៧១ | ៣១៧ |
| | អត្រាប្តូរប្រាក់បរទេស | - | - | - | - | - | ៣០ |
| | ប្រតិបត្តិការនិងគោលនយោបាយរូបិយវត្ថុ | ៣២ | ២៦១ | ២៦០ | ១៧៨ | - | - |
| | ការគ្រប់គ្រងបេឡា | - | - | - | - | - | - |
| | ផ្នែកផ្សេងៗជាច្រើន | - | - | ៦០ | - | ៥៥ | ៦៥ |
| | **សរុប** | **៩៦** | **២៦១** | **៣២០** | **៣៥០** | **៣២៦** | **៤២២** |
| FAD | ចរិការធនាគារ | - | - | - | - | ២៤២ | ២៦៤ |
| | ពហុ ប្រធានបទ សារពើពន្ធ | - | - | - | ៤ | ១៣ | - |
| | ការគ្រប់គ្រងចំណាយសាធារណៈ | - | - | - | ១៣៨ | ៧ | ៥ |
| | រដ្ឋបាល គយ និងពន្ធដារ | ៦៧ | - | ៨៥ | ២២៨ | ៥៥៣ | ៧៤៥ |
| | ផែនការសកម្មភាពសហប្រតិបត្តិការបច្ចេកទេស | - | - | ១២៨ | ២៣ | - | - |
| | ផ្នែកផ្សេងៗជាច្រើន | ៨១ | - | - | - | - | ៤៧ |
| | **សរុប** | **១៤៨** | **-** | **២១៣** | **៣៩៣** | **៨១៥** | **១០៨៧** |
| STA | ស្ថិតិជញ្ជីងទូទាត់ | ៧ | - | ២០ | ៣៩ | ១៣ | ១៨៣ |
| | ការគ្រប់គ្រងនិង បទបញ្ញត្តិធនាគា | - | - | - | ៧ | - | - |
| | ផ្នែកផ្សេងៗជាច្រើន | ៩ | ២២ | ១៤ | ៣៧ | ១៨៣ | ២៧៥ |
| | **សរុប** | **១៦** | **២២** | **៣៤** | **៨៣** | **១៩៦** | **៤៥៨** |
| LEG | សារពើពន្ធ | - | - | - | - | ៥ | ២០ |
| | ប្រធានបទ ជាច្រើន | - | - | ១៤ | ២៩ | ៣៩ | ៣១ |
| | ផ្សេងៗ | - | - | ៧ | ២៩ | ៣០ | ១៨ |
| | ការចំណាយ និងការដោះស្រាយ | - | - | - | - | ១០ | |
| | សរុប | - | - | ២១ | ៥៨ | ៨៤ | ៦៩ |
| | **សរុបដុល** | **២៦០** | **២៨៣** | **៥៨៨** | **៨៨៣** | **១៤២០** | **២០៣៦** |

ប្រភព: OTM និង TIMS

១/ជំនួយបច្ចេកទេសបានផ្តល់អោយតែក្នុងផ្នែកប៉ុណ្ណោះ ។ សំរាប់ជំនាញការ និង បេសកកម្មរយៈពេលខ្លី (តិចជាង ៦ខែក្នុងផ្នែកមួយ) ទិន្នន័យរួមទាំងថ្ងៃចុងសប្តាហ៍ ។ សំរាប់ជំនាញរយៈពេលវែងថ្ងៃចុងសប្តាហ៍មិនត្រូវបានរាប់បញ្ចូលទេ ។

៦- ក្នុងរយៈពេលបីឆ្នាំ បន្ទាប់ពីការចាប់ផ្តើមនៃកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស ឥទ្ធិពលជ្រួតជ្រាបនៃជំនួយបច្ចេកទេសនៅក្នុងវិស័យផ្សេងៗគ្នា មានកំរិតខុសៗគ្នាគួរអោយកត់សំគាល់ ។ កំណែទំរង់ផ្នែកធនាគារត្រូវបានចាត់ទុកថាទទួលបានជោគជ័យ ។ កម្មវិធីផ្តល់អាជ្ញាប័ណ្ណឡើងវិញ អនុវត្តដោយធនាគារជាតិនៃកម្ពុជាបានកែប្រែប្រព័ន្ធ

ធនាគារ ដោយបានកាត់បន្ថយចំនួនធនាគារពី ៣១ មកត្រឹម ១៧ ហើយជួយស្តារឡើងវិញនូវភាពទុកចិត្តបាន របស់ធនាគារ [4] ។ ជាការឆ្លើយតបទៅនឹងទំនុកចិត្តពីសាធារណៈជន ចំពោះប្រព័ន្ធធនាគារដែលមានភាពប្រសើរឡើងជាលំដាប់ បានឆ្លុះបញ្ចាំងតាមរយៈការកើនឡើងប្រាក់បញ្ញើ ២៧% ក្នុងកំឡុងឆ្នាំ ២០០២ ហើយនឹងកើនច្រើនជាងនេះក្នុងឆ្នាំ ២០០៣ [5]។ ម៉្យាងទៀត ភាពខុសគ្នារវាងអត្រាកម្ចីកាន់តែតូចទៅៗក្នុងឆ្នាំ២០០៣ ដោយសារការប្រកួតប្រជែងក្នុងទីផ្សារនេះ កាន់តែមានសភាពខ្លាំងឡើង ។ ចំពោះការគ្រប់គ្រងវិញ ក្រុមអធិការកិច្ចពីរក្រុមទទួលបានការបណ្តុះបណ្តាល ដោយមួយក្រុមសំរាប់អធិការកិច្ចនៅនឹងកន្លែង និង មួយក្រុមទៀតសំរាប់មើលពីលើការអនុវត្តន៍ អោយស្របទៅតាមប្លង់គណនេយ្យ (COA)ថ្មីមួយ ។ ការអនុវត្តន៍ប្លង់គណនេយ្យថ្មីនេះ សង្ឃឹមថានឹងធ្វើទាំងស្រុងនៅចុងឆ្នាំ ២០០៤ ហើយការពង្រឹងនូវបទបញ្ញត្តិបានបង្ខំអោយធនាគារពាណិជ្ជកម្មបង្កើននូវមូលធនរបស់ខ្លួន [6] ។ បញ្ហាមួយនៃបញ្ហាទាំងឡាយ ដែលមិនទាន់បានសម្រេច គឺការធ្វើឯកជនភាវូបនីយកម្មធនាគារពាណិជ្ជកម្មក្រៅប្រទេស ។ ការគ្រប់គ្រងធនាគាររដ្ឋនេះ គឺត្រូវបានផ្ទេរពីធនាគារជាតិ ទៅអោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ហើយឯកជនភាវូនីយកម្មកំពុងដំណើរការ ទោះបីជាដំបូន្មានដែលបានផ្តល់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិទាំងអស់ មិនបានអនុវត្តន៍តាមទាំងអស់ក៏ដោយ ។

៧- សរុបសេចក្តីមក ទោះបីជាមានការប្រឈមយ៉ាងច្បាស់ចំពោះមុខ និង ភាពខ្វះខាតខ្លះក៏ដោយក្តី យើងអាចនិយាយបាន ដោយយុត្តិធម៌ថា ជំនួយបច្ចេកទេសក្នុងវិស័យកំណែទំរង់ធនាគារដែលបាននាំមកនូវការពង្រឹងប្រព័ន្ធធនាគារ និង បង្កើតជាមូលដ្ឋានគ្រឹះ ដើម្បីអោយមានតួនាទីធំធេងនៃប្រព័ន្ធហិរញ្ញវត្ថុ ដើម្បីជាការជំរុញអោយមានកំណើនសេដ្ឋកិច្ច នៅប្រទេសកម្ពុជា ។ ឥទ្ធិពលជ្រួតជ្រាបនៃជំនួយការបច្ចេកទេសក្នុងកំណែទំរង់ធនាគារ គឺទទួលបានការពេញចិត្ត។

៨- កំណែទំរង់ក្នុងផ្នែកស្ថិតិសេដ្ឋកិច្ចបានបង្ហាញអោយឃើញថាមានការរីកចំរើនខ្លាំងគួរសម [7] ។សព្វថ្ងៃ កម្ពុជាបានបំពេញនូវតំរូវការភាគច្រើនសំរាប់ទិន្នន័យ GDDS ។ មានការកែលំអរច្រើនពីភាពដែលអាចរកបាន និង គុណភាពនៃទិន្នន័យដែលត្រូវការសំរាប់ចងក្រងគណនីជាតិ ស្ថិតិថ្លៃ ជញ្ជីងទូទាត់ និង ស្ថិតិរូបិយវត្ថុ ក៏ដូចជាសូចនាករសេដ្ឋកិច្ច-សង្គម ។ វិទ្យាស្ថានជាតិស្ថិតិជាតិបានពង្រីកការប្រមូលទិន្នន័យថ្លៃសំរាប់ ៥ ក្រុង និងបង្កើតសន្ទស្សន៍ថ្លៃប្រើប្រាស់ ដោយធ្វើអោយស៊ីគ្នារវាងទិន្នន័យសើរីឆ្នាំ ២០០០ និង ឆ្នាំ ១៩៩៤។ លើសពីនេះទៅទៀត វិធីសាស្ត្រដែលប្រើប្រាស់ក្នុងការចងក្រងគណនីជាតិ និង ថ្លៃ ជញ្ជីងទូទាត់ និង ស្ថិតិរូបិយវត្ថុ ត្រូវបានធ្វើការពិនិត្យឡើងវិញ និង បាន ធ្វើការពង្រឹង ។ សៀវភៅស្ថិតិប្រចាំឆ្នាំក៏បានធ្វើការពង្រីកមាតិការផងដែរ។ អាជ្ញាធរមានភាពស្វយ័តរួចមកហើយក្នុងការកែលំអ និង ការពង្រីកទិន្នន័យទាំងនោះ អាស្រ័យហេតុនេះ ការផ្លាស់ប្តូរជាវិជ្ជមានទាំងនេះរំពឹងថា នឹង

---

[4] ការពិពណ៌នាពីដំណើរការផ្តល់អាជ្ញាប័ណ្ណឡើងវិញ អាចត្រូវរកឃើញនៅក្នុង De Zamarozcy and Sa. គោលនយោបាយសេដ្ឋកិច្ចក្នុង សេដ្ឋកិច្ចដុល្លារូបនីយកម្មខ្ពស់» ២០០៣ ។

[5] សូមមើលមូលនិធិរូបិយវត្ថុអន្តរជាតិ « មាត្រាទី ៤ » (២០០២) ហើយនិង Frydl, Edward, Juan Foxley, and Eddie Herron, "វិស័យធនាគារ និង បញ្ហាគណនេយ្យ និង ការគ្រប់គ្រងនៃទីផ្សារប្តូរប្រាក់បរទេសបំរុង» (២០០៣)។

[6] រដ្ឋាភិបាលកម្ពុជា «កម្ពុជា : របាយការណ៍ដំណើរការកម្មវិធីសហប្រតិបត្តិការជំនួយការបច្ចេកទេស» ២០០៣ ។

[7] មើលរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០០៣ និង UNCTAD « របាយការណ៍វាយតំលៃស្តីពី កម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស ស្តីពីការពង្រឹងសេដ្ឋកិច្ច និងការគ្រប់គ្រងហិរញ្ញវត្ថុ» ២០០៤។

មាននិរន្តរភាព ។ ក៏ប៉ុន្តែ មានបញ្ហាតឹងតែងមួយចំនួនកំពុងរារាំងដំណើរការនៅក្នុងស្ថាប័នដ៏ទៃផ្សេងទៀត ។ ក្នុងករណីខ្លះ ការផ្ទេរនូវចំណេះដឹងមានការយឺតយ៉ាវពីព្រោះបុគ្គលិកនៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើការមិនពេញម៉ោង ដែលបញ្ហាទាំងនេះមានការពិបាកយ៉ាងខ្លាំងក្នុងការបង្កើតស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល ។ បញ្ហាផ្សេងទៀតគឺខ្វះមូលនិធិ ។ លើកលែងតែធនាគារជាតិនៃកម្ពុជា ពុំមានស្ថាប័នណាបានបែងចែកថវិកាចំណាយ សំរាប់ការប្រមូលទិន្នន័យស្ថិតិ ចាំបាច់អោយបានទៀងទាត់ទេ ។ ការប្រមូលទិន្នន័យសំរាប់គណនីជាតិ និង ទិន្នន័យពីថ្លៃភាគច្រើនទទួលបាន មូលនិធិពីធនាគារអភិវឌ្ឍន៍អាស៊ី ។

៩- សរុបមក ទោះបីជាថវិកានិងប្រភពធនធានមនុស្សនៅមានកំរិតក៏ដោយ ជំនួយបច្ចេកទេសក្នុងកំណែទំរង់ស្ថិតិសេដ្ឋកិច្ច បានជួយធ្វើអោយប្រសើរឡើងនូវបរិមាណ និង គុណភាពស្ថិតិយ៉ាងច្រើន ហើយបានផ្ទេរចំណេះដឹងទៅរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព ដែលអាចធ្វើអោយវឌ្ឍនភាពនេះមានចិរភាពដោយខ្លួនឯង ។ ដូចជាក្នុងករណីកំណែទំរង់ធនាគារ ទោះបីជានៅតែមានភាពប្រឈមចំពោះមុខជាច្រើនសំខាន់ៗក៏ដោយក្តី ក៏ជំនួយបច្ចេកទេសសំរាប់ ស្ថិតិសេដ្ឋកិច្ចបង្ហាញពីមានឥទ្ធិពលជ្រួតជ្រាបជាវិជ្ជមាន ។

១០- ក្នុងវិស័យកំណែទំរង់ផ្នែកសារពើពន្ធ ឥទ្ធិពលជ្រួតជ្រាបនៃជំនួយបច្ចេកទេសនៅមានកំរិតខ្សោយ ទោះបីជាមានដំណើរការគួរអោយកត់សំគាល់ខ្លះក្នុងការពង្រឹងរដ្ឋបាលពន្ធដារ និងគយ ជាពិសេសទៅលើរចនាសម្ព័ន្ធនិងនីតិវិធី។ បញ្ហាថវិកាដែលកើតមានតាំងពីយូរ ហើយភាពប្រឈមរបស់កម្ពុជា គឺការប្រមូលពន្ធមិនបានគ្រប់គ្រាន់ ។ ក្នុងឆ្នាំ ២០០៣ ចំណូលពន្ធសរុបគិតជាភាគរយនៃផលិតផលដុលក្នុងស្រុកមានចំនួនតែ ៧.៣% ប៉ុណ្ណោះ ដែលជាបរិមាណមួយមានកំរិតទាបក្នុងពិភពលោក ហើយតួលេខនេះបានធ្លាក់ចុះពី ៧.៨% នៃផ.ស.ស ក្នុងឆ្នាំ ២០០១ ទោះបីជាសេដ្ឋកិច្ចបានរីកធំឡើងជាប្រចាំក្តី (រូបទី១)។ ទាំងនេះបណ្តាលមកពីការធ្លាក់ចុះចំណូល ពីអាករលើតំលៃបន្ថែម និង ចំណូលពន្ធពាណិជ្ជកម្ម ទោះបីជាជំនួយបច្ចេកទេសខិតខំប្រឹងប្រែងពង្រឹងរដ្ឋបាលពន្ធដារ និងគយ ព្រមទាំងបានបង្កើនចំណាត់ការមួយផងក៏ដោយ ។ ដោយគ្មានមន្ទិលសង្ស័យ ភាពមានកំរិតនៃរដ្ឋបាលបាននាំអោយទទួលបានលទ្ធផលបែបនេះ ។ បញ្ហាអភិបាលកិច្ច និងអំពើពុករលួយបានបង្អាក់ការអនុវត្តន៍ច្បាប់ពន្ធដារអោយបានពេញលេញ ព្រមទាំងធ្វើអោយខូចដល់មូលដ្ឋានពន្ធដារ តាមរយៈការផ្តល់ការលើកលែងពន្ធ ដែលគ្មានតម្លាភាព ទៅអោយវិស័យឯកជន [8] ។ ចំពោះគយ ជំនួយបច្ចេកទេសជួបប្រទះការលំបាកស្រដៀងគ្នានេះដែរ ។ កិច្ចខិតខំប្រឹងប្រែង ដើម្បីធ្វើការកែទំរង់និងបញ្ចូលនូវប្រតិបត្តិការ បន្តរងផលប៉ះពាល់ជាអវិជ្ជមានដោយសារតែបៀវត្សបុគ្គលិកមានកំរិតទាប ហើយពួកគេនៅបន្តជីវិតយក «កំរៃមិនផ្លូវការ» ជាបន្តទៀត ។ អំពើរត់ពន្ធកាន់តែក្លាយជាបញ្ហាធ្ងន់ធ្ងរហើយធ្វើអោយបាត់ចំណូលសារពើពន្ធជាច្រើន [9] ។ ផលប៉ះពាល់មិនល្អនៃបញ្ហាទាំងនេះ បន្តធ្វើអោយក្រិនដល់ឥទ្ធិពលវិជ្ជមានមួយចំនួនដែលកើតពីប្រសិទ្ធិភាពរដ្ឋបាល (មានន័យថា កាត់បន្ថយចំនួនថ្ងៃសំរាប់កុងទែនើរដែលត្រូវត្រួតពិនិត្យផ្នែកពន្ធ) ។ ការលំបាកសំរាប់សារពើពន្ធ គឺមិនមែនត្រឹមតែចំណូលមួយមុខទេ ។ ភាពរីកចំរើននៅក្នុងការគ្រប់គ្រងថវិកា នៅមានភាពយឺតយ៉ាវនៅឡើយ ប្រតិបត្តិការថវិកាមានបញ្ហាដោយកង្វះសាច់ប្រាក់ ការពន្យារពេលក្នុងការអនុម័តចំណាយ ហើយនិងការកើនឡើងនូវបំណុលមិនទាន់ទូរទាត់ [10] ។

[8] IMF, "Cambodia, Ex Post Assessment of Longer-Term Program Engagement" (2004)

[9] សូមមើល រាជរដ្ឋាភិបាលកម្ពុជា (២០០៣)

[10] IMF, "Fiscal Strategy Brieg, Fiscal Affairs Department" (2003)

រូបទី ១ លទ្ធផលអនុវត្តន៍ក្នុងផ្នែកសារពើពន្ធ







*ប្រភព: APD*

បទពិសោធន៍ផ្ទុយគ្នា រវាងជំនួយបច្ចេកទេសសំរាបវិស័យធនាគារ និង ស្ថិតិ ប្រៀបធៀបនឹងជំនួយបច្ចេកទេសសំរាប់វិស័យសារពើពន្ធជាឱកាសល្អមួយ ដើម្បីទាញចេញជាមេរៀនខ្លះស្តីអំពីអ្វីគឺជាកត្តាដែលជះឥទ្ធិពលដល់ប្រសិទ្ធិភាពជំនួយបច្ចេកទេស ។ ប្រការទាំងនេះនឹងត្រូវយកមកដោះស្រាយក្នុងផ្នែកបន្ទាប់ ដែលយើងនឹងពិភាក្សាលំអិតពីប្រភពសំខាន់ៗ ដែលនាំអោយមានឥទ្ធិពលផ្សេងៗគ្នាលើភាពជ្រួតជ្រាបរបស់ជំនួយបច្ចេកទេសនៅប្រទេសកម្ពុជា ។ យើងក្រឡេកមើលទៅលើសំនុំនៃកត្តាពីរ ។ សំនុំទីមួយ ជាកត្តាប្រទេសដែលមិនឋិតនៅក្រោមការគ្រប់គ្រងដោយផ្ទាលរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ នៅក្នុងសំនុំនេះ កង្វះខាតឆន្ទៈនយោបាយ និង កង្វះខាតនូវត្តនាទីមន្ត្រីរាជការនឹងត្រូវលើកមកពិនិត្យ ។ សំនុំទីពី ជាកត្តាទាំងឡាយណាដែលឋិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីមូលនិធិរូបិយវត្ថុអន្តរជាតិ រួមមាន : ការធ្វើវិនិច្ឆ័យលើការសម្របសម្រួលមធ្យោបាយក្នុងការបែងចែក និង ការតាមដាន។

## ៣. កត្តាផ្ទៃក្នុងប្រទេសដែលជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃជំនួយបច្ចេកទេស

១១- ការខិតខំប្រឹងប្រែងកសាងសមត្ថភាពទទួលនូវឥទ្ធិពលយ៉ាងខ្លាំង ពីអថេរ ឬ អាញត្តិស្ថាប័នក្នុងស្រុក និងនយោបាយ ។ សំនួរចោទឡើងថាតើជំនួយបច្ចេកទេសមានឥទ្ធិពល ឬ អត់ គឺអាស្រ័យយ៉ាងខ្លាំងទៅលើឆន្ទៈនយោបាយរបស់អាជ្ញាធររដ្ឋាភិបាល ក្នុងការអនុវត្តន៍បានសម្រេចនូវអនុសាសន៍ទាំងឡាយ ព្រមទាំងលទ្ធភាពរបស់មន្ត្រីក្នុងស្រុកខ្លួនឯងក្នុងការទទួលយក និង អនុវត្តន៍អនុសាសន៍ទាំងនោះ ។ ដូចដែលយើងនឹងបង្ហាញ បើសិនជាអាជ្ញាធរមិនប្តេជ្ញាចិត្តអោយបានមាំទាំនឹងធ្វើទៅតាមអនុសាសន៍របស់ជំនួយបច្ចេកទេសទេ ឬ បើសិនមន្ត្រីរដ្ឋាភិបាលមានលទ្ធភាពតិចតួចនឹងទទួលយកនោះ លទ្ធភាពជ្រួតជ្រាបរបស់ជំនួយបច្ចេកទេសនឹងមានដែនកំណត់ ។ ផ្ទុយទៅវិញបើសិនជាបុរេលក្ខខ័ណ្ឌវិនិច្ឆ័យទាំងពីរនេះអាចបំពេញបាន នោះលទ្ធភាពជ្រួតជ្រាបរបស់ជំនួយបច្ចេកទេស នឹងកើនឡើងយ៉ាងខ្លាំង ។

### ក. ឆន្ទៈនយោបាយ និង ការប្តេជ្ញាចិត្តនឹងអនុវត្តន៍

១២- ឆន្ទៈនយោបាយក៏ជាកត្តាដែលមិនអាចខ្វះបានដើម្បីអោយជំនួយបច្ចេកទេសទទួលបានជោគជ័យ។ បើគ្មានវាទេ នោះអនុសាសន៍ទាំងឡាយនឹងជ្រួតជ្រាបក្នុងដែនកំណត់មួយប៉ុណ្ណោះ ។ ឧទាហរណ៍ដ៏ល្អមួយ គឺថាមានភាពលំបាកជាច្រើនដែលត្រូវប្រឈមមុខក្នុងការកែទំរង់រដ្ឋបាលពន្ធកាលពីឆ្នាំកន្លងទៅ ។ ការខំប្រឹងដើម្បីធ្វើការកែទំរង់នាយកដ្ឋាន

នេះ រាំងស្ទះជាទូទៅដោយសារតែអំពើពុករលួយ និង អំពើរត់ពន្ធដ៏គគ្រឹកគគ្រេង។ គោលបំណងទាំងឡាយក្នុងការបញ្រ្ជាប ដំណើរការពន្ធគយត្រូវបានបំពុលដោយសារតែបុគ្គលិកនៅតែត្រូវការ «កំរៃក្រៅផ្លូវការ» ក្នុងការធ្វើឯកសារទាំងឡាយ ក៏ដូចជាក្នុងការជំរះការដឹកជញ្ជូនទំនិញ។ ទំរង់នៃអំពើពុករលួយបែបនេះបង្កើតជាអំរែកក្នុងការធ្វើពាណិជ្ជកម្ម ព្រមទាំងជាឧបសគ្គដ៏ចំបងក្នុងការបញ្រ្ជាបចូលរបស់និតិវិធីពន្ធគយ។ អំពើរត់ពន្ធធ្វើអោយចំណូលបាត់បង់ច្រើនគួរសម និង បង្កើតអោយមានការប្រកួតប្រជែងមិនយុត្តិធម៌ សំរាប់អាជីវកម្មទាំងឡាយដែលស្របច្បាប់ហើយ ត្រូវបង់ពន្ធ។ សំណាងមិនល្អ ការខំប្រឹងក្នុងការដោះស្រាយបញ្ហានេះជួបប្រទះនូវឧបសគ្គ ដោយសារតែមានជាប់ទាក់ទងនឹងផលប្រយោជន៍ធំៗ និង ក្រុមរត់ពន្ធដែលមានចរិតជាការរៀបចំខ្ពស់[11]។ ការប្តេជ្ញា និង ការសម្របសម្រួលពីថ្នាក់លើត្រូវអោយមាន ដើម្បីបញ្ឈប់នូវសកម្មភាពខុសច្បាប់ទាំងនេះ មុនពេលដែលជំនួយបច្ចេកទេសអាចនឹងជ្រួតជ្រាបបានពេញលេញ [12]។

១៣- ករណីផ្ទុយមួយគឺការសំរេចជោគជ័យលើការផ្តល់អាជ្ញាប័ណ្ណឡើងវិញទៅអោយធនាគាពាណិជ្ជទាំងឡាយ នឹងការស្តារឡើងវិញ នូវភាពអាចទុកចិត្តបាននៅក្នុងវិស័យធនាគារ ដែលជាការទាញយកប្រយោជន៍ពីជំនួយបច្ចេកទេសដែលត្រូវបានផ្តល់អោយនៅក្នុងវិស័យនេះ។ ទោះបីជារឿងទាំងនេះជាចំណុចរសើបផ្នែកនយោបាយក៏ដោយ ឥឡូវនេះមានតែធនាគារចំនួនតែ១៧ប៉ុណ្ណោះ ដែលកំពុងដំណើរការនៅកម្ពុជា បើធៀបទៅនឹងចំនួនជាង៣០កាលពីមុន។ ការផ្តល់អាជ្ញាប័ណ្ណឡើងវិញ បានធ្វើឡើងដោយមិនមានការបាត់បង់ទំនុកចិត្តពីសាធារណជន ដែលបង្ហាញដោយប្រាក់បញ្ញើរមិនបានធ្លាក់ចុះក្នុងកំឡុងពេលដំណើរការនោះ។ និយាយជាទូទៅ ភាពទុកចិត្តបាននៅក្នុងវិស័យធនាគារមានការប្រសើរឡើងយ៉ាងច្បាស់ ឆ្លុះបញ្ចាំងដោយធនាគារដែលផុតពីការរងគ្រោះទាំង១៧ មានទុនបម្រុងកើនឡើង និង ប្រតិបត្តិតាមប្លង់គណនេយ្យថ្មី ។ ចំណុចសំខាន់បំផុតនៃជោគជ័យក្នុងកំណែទំរង់នេះ គឺបានមកដោយសារភាពជាអ្នកដឹកនាំដែលប្រតិបត្តិដោយថ្នាក់ដឹកនាំធានាគាជាតិនៃកម្ពុជា ដែលត្រូវបានបញ្ចុះបញ្ចូលអោយដើរតាមដំណើរការផ្តល់អាជ្ញាប័ណ្ណឡើងវិញនេះជាដំរាបទៅអោយថ្នាក់លើបន្តទៀត ទោះបីជាមានទំនាស់ជាផលប្រយោជន៍ច្រើនកើតមានក្តី ។ លើសពីនេះទៅទៀត អគ្គនាយកធានាគារជាតិនៃកម្ពុជាតែងតែមានទំនាក់ទំនងជាប្រចាំជាមួយសមាជិកសភា- ព្រឹទ្ធសភា និង អ្នកនយោបាយសំខាន់ៗ ដោយព្យាយាមអធិប្បាយអំពីករណីនៃកំណែទំរង់នេះ ។

១៤.- បទពិសោធន៍ផ្ទុយគ្នារវាងការកែទំរង់ពន្ធ និង ការផ្តល់អាជ្ញាប័ណ្ណឡើងវិញទៅអោយធនាគារពាណិជ្ជ បង្ហាញអោយឃើញថា មានការទាក់ទងយ៉ាងខ្លាំងទៅនឹងការប្តេជ្ញាផ្នែកនយោបាយ ដើម្បីបង្កើននូវភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេស ។ ការប្តេជ្ញារបស់អាជ្ញាធរក្នុងការអនុវត្តន៍ទៅតាមអនុសាសន៍របស់ជំនួយបច្ចេកទេស គឺជាការចាំបាច់ហើយជាលក្ខ័ណ្ឌគន្លឹះសំរាប់ភាពជោគជ័យរបស់ជំនួយបច្ចេកទេស ។ មេរៀនដ៏ច្បាស់មួយដែលបានរៀនសូត្រពីបទពិសោធន៍នេះគឺថា មូលនិធិរូបិយវត្ថុអន្តរជាតិគួរតែវិភាគដោយប្រុងប្រយ័ត្ន នូវការប្តេជ្ញាចិត្តផ្នែកនយោបាយរបស់អាជ្ញាធរ មុនពេលដែលផ្តល់ធនធានអោយ ព្រមទាំងមើលអោយលំអិតលើកំណត់ត្រានៃការអនុវត្តន៍ពីពេលមុនៗ ។

---

[11] រាជរដ្ឋាភិបាលកម្ពុជា (២០០៣)

[12] ក្នុងករណីប្រទេសកម្ពុជា ហានិភ័យពីអំពើពុករលួយនៅក្នុងប្រព័ន្ធពន្ធមានកំរិតខ្ពស់ ដោយសារ មន្ត្រីរាជការទទួលប្រាក់ខែទាប ផលធៀបអាហារណាទៅនឹងផ.ស.សខ្ពស់ និង មានការពឹងផ្អែកច្រើនទៅលើពន្ធដារជាប្រភពចំណូលសាធារណៈ។ នៅកម្ពុជាប្រភពសំខាន់នៃកំណើនសេដ្ឋកិច្ច សំរាប់ប៉ុន្មានឆ្នាំចុងក្រោយនេះ គឺដោយសារតែការរីកធំធាត់នៃពាណិជ្ជកម្មក្រៅប្រទេសហើយប្រភពចំណូលសាធារណៈសំខាន់បំផុតគឺបានមក ពីពន្ធដារ។

នៅក្នុងបរិយាការណ៍នេះ ការទុកនូវកំណត់ត្រាការអនុវត្តន៍លំអិតពីបទពិសោធន៍ជំនួយបច្ចេកទេសនៅតាមប្រទេសផ្សេងៗជាប្រយោជន៍ដើម្បីជាព័ត៌មានសំរាប់ប្រទេសផ្សេងៗទៀត ក្នុងការធ្វើសេចក្តីសំរេចចិត្តក្នុងការបែងចែកធនធានទាំងឡាយ ។ នេះបញ្ជាក់ពីតំរូវការអោយមានការបង្កើតនូវប្រព័ន្ធត្រួតពិនិត្យដ៏មានប្រសិទ្ធិភាព ដើម្បីវាយតំលៃថាតើអនុសាសន៍ជំនួយបច្ចេកទេសដែលមានពីមុនមក មានអ្វីខ្លះបានអនុវត្តហើយអ្វីខ្លះមិនទាន់បានអនុវត្ត ។

១៥- នៅពេលដែលអាជ្ញាធរមិនបានអនុវត្តអោយបានពេញដៃពេញជើង ទៅតាមអនុសាសន៍របស់ជំនួយបច្ចេកទេសទេនោះ ជំនាញការនៃជំនួយបច្ចេកទេស និង ការិយាល័យកណ្តាលរបស់ពួកគេ គួរតែរាយការណ៍ពីស្ថានភាពនេះ បើមិនដូច្នេះទេ លទ្ធភាពក្នុងការចាត់វិធានការណ៍បង្ការនឹងមិនអាចធ្វើទៅបាន ហើយការសំរេចចិត្តនាពេលអនាគតអាចនឹងត្រូវពឹងផ្អែកទៅលើព័ត៌មានដែលខុស ។ ប្រយោជន៍ដ៏សំខាន់បំផុតនៃជំនួយបច្ចេកទេស គឺធ្វើអោយមានតម្លាភាពតាមតែអាចធ្វើទៅបាន នៅពេលដែលជំនួយបច្ចេកទេសត្រូវបានរារាំងដោយកិច្ចសហប្រតិបត្តិការមិនល្អ ឬក៏បង្ករឧបសគ្គជាចំហរដោយអាជ្ញាធរ ។

## ខ. សារៈសំខាន់នៃមន្ត្រីមុខងារសាធារណៈដែលប្រតិបត្តិបានល្អៈ ករណីសិក្សាពីស្ថិតិពហុវិស័យ

១៦- តួនាទីដ៏សំខាន់នៃគុណភាពស្ថាប័នសាធារណៈក្នុងការសំរេចអោយបាននូវសេដ្ឋកិច្ចនិងនយោបាយដ៏ល្អមួយ ត្រូវបានគេទទួលស្គាល់ច្រើនឡើងៗ ។ សមត្ថភាពរបស់មន្ត្រីជំនាញដែលប្រកាន់ខ្ជាប់ទៅនឹងក្រមសីលធម៌ ជាលក្ខខ័ណ្ឌចាំបាច់មួយដើម្បីធ្វើអោយបរិស្ថានគោលនយោបាយអំណោយផលដល់កំណើនសេដ្ឋកិច្ច ។ មិនមានអ្វីគួរអោយភ្ញាក់ផ្អើលទេ ដែលមានការសិក្សាជាច្រើនបានធ្វើឡើង ដើម្បីអាចយល់ពីគ្រឿងផ្សំទាំងឡាយសំរាប់ផលិតអោយបានសេវាកម្មសាធារណៈដ៏ល្អមួយ ក្នុងចំណោមនេះមានការបរិយាយបីដែលមានសង្គតិភាពៈ ការជ្រើសរើសបុគ្គលិកតាមគុណូបធិបតេយ្យ ប្រាក់ខែដែលមានការប្រកួតប្រជែង និង ការដំឡើងឋានៈតួនាទីផ្ទៃក្នុង ព្រមទាំងស្ថេរភាពនៃអាជីព[13]។

១៧- ការិយាល័យធិបតេយ្យនៅកម្ពុជាខ្វះខាតនូវលក្ខណៈសម្បត្តិទាំងនេះ។ លើកលែងតែធនាគារជាតិនៃកម្ពុជា មន្ត្រីរាជការទទួលបានប្រាក់ខែទាប នឹងមិនមានលំនឹងច្បាស់លាស់ពីអាជីព តំណែងត្រូវបានផ្តល់អោយទៅតាមខ្សែរយៈនយោបាយ ហើយគួរបដិបក្ខផ្ទែកនយោបាយត្រូវប្រឈមមុខយ៉ាងជូរចត់រវាងនាយកដ្ឋាននានា សូម្បីតែនៅក្នុងក្រសួងជាមួយគ្នា ។ ជាលទ្ធផល មន្ត្រីមុខងារសាធារណៈភាគច្រើនមានជំនាញទាប ហើយមានការងារបន្ថែមមួយ ឬពីរទៀត ដើម្បីបំពេញចំណូលរបស់ពួកគេ អត្រាផ្ទេរ/លះបង់ការងារមានសភាពខ្ពស់ខ្លាំង ហើយមានការលំបាកយ៉ាងខ្លាំងក្នុងការរក្សាមន្ត្រីរាជការដែលមានសមត្ថភាព ។ ជាងនេះទៀត មន្ត្រីមុខងារសាធារណៈដែលមានជំនាញត្រូវបានប្រើប្រាស់លើការងារច្រើនហួសកំរិត និង កំពុងតស៊ូនឹងកិច្ចការច្រើនជំពូក ។

១៨- លទ្ធភាពជ្រួតជ្រាបនៃអនុសាសន៍ពីជំនួយបច្ចេកទេសត្រូវប្រឈមនឹងឧបសគ្គជាប្រចាំ ដោយសារគុណវិបត្តិទាំងអស់នេះ ។ ជំនាញការមូលនិធិរូបិយវត្ថុអន្តរជាតិ កម្ររកបានមន្ត្រីដៃគូរដែលធ្វើការពេញម៉ោងណាស់ ហើយជៀសមិនផុតពីភាពយឺតយ៉ាវក្នុងការផ្ទេរចំណេះដឹង ហើយម្យ៉ាងទៀត មានករណីខ្លះទៀត មន្ត្រីដៃគូរនៅមានកំរិត

---

[13] សូមមើល Evans Peter, Rauch James, “Bureaucratic Structure and Bureaucratic Performance in Less Developed Countries” (2000).

ជំនាញទាបពេក ។ បញ្ហាមួយទៀត នៅពេលដែលមន្ត្រីដែគួរបានបណ្តុះបណ្តាលរួចហើយ ពួកគេតែងតែរត់ទៅផ្នែកឯកជនដើម្បីទទួលបានប្រាក់បៀវត្សខ្ពស់ ។ ជាលទ្ធផល ការអនុវត្តន៍បែបនេះ ធ្វើអោយដំណើរការកសាងសមត្ថភាពមានសភាពយឺតយ៉ាវ ។ ប៉ុន្តែមន្ត្រីមុខងារសាធារណៈកម្ពុជាមានប្រភពខុសៗគ្នា ដែលភាពខុសគ្នា ឬ វិសភាគនេះនៅក្នុងសមត្ថភាពរបស់ពួកគេ បង្កការលំបាកក្នុងការទទួលយកជំនួយបច្ចេកទេស ដែលគប្បីត្រូវទទួលស្គាល់ ។ លើសពីនេះ ភាពខុសគ្នាទាំងនេះអាចផ្តល់នូវជាបទពិសោធន៍ល្អ សំរាប់ការសិក្សាពីផលប៉ះពាល់លើប្រសិទ្ធិភាពរបស់ជំនួយបច្ចេកទេសទៅលើគុណភាពនៃសេវាកម្មសាធារណៈ ។

១៩- បំរែបំរួលទាំងឡាយនៃគុណភាពសេវាកម្មសាធារណៈ និងឥទ្ធិពលរបស់វាទៅលើប្រសិទ្ធិភាពនៃជំនួយបច្ចេកទេសអាចលើកជាឧទាហរណ៍បានយ៉ាងល្អ ដោយប្រៀបធៀបជំនួយបច្ចេកទេសដែលផ្តល់អោយភ្នាក់ងារបីផ្សេងៗគ្នា មានធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងវិទ្យាស្ថានជាតិស្ថិតិ[14] ។ ក្នុងចំណោមស្ថាប័នទាំងបីធនាគារជាតិនៃកម្ពុជាមានបុគ្គលិកដែលមានសមត្ថភាពច្រើនជាង ហើយក៏រៀតរៀបចំស្ថាប័នមានសភាពល្អដាច់គេនៅកម្ពុជា ។ ប្រាក់បៀវត្សត្រូវបានទូរទាត់ទាន់ពេលវេលា និង មានចំនួនច្រើនជាងមន្ត្រីរាជការដ៏ទៃទៀត [15] ជាមួយនឹងការបង្កើតនូវខ្សែអាជីពយ៉ាងល្អ ថែមទាំងមានប្រព័ន្ធលើកទឹកចិត្តដែលអ្នកគ្រប់គ្នាដឹងព្រមទាំងអាចទទួលបានការអប់រំបន្ថែមទៀត ។ ជាលទ្ធផល អត្រាលះបង់/ផ្ទេរការងារមានកំរិតទាប ហើយមន្ត្រីធ្វើការងារពេញម៉ោង និង មានជំនាញគិតជាមធ្យមខ្ពស់ជាងវិស័យសាធារណៈដ៏ទៃទៀត។ មិនជារឿងគួរអោយចំលែកទេ ដែលថាភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេសមានទំហំធំជាងកន្លែងផ្សេងៗទៀត ។ មានភាពរីកចំរើនយកជាការបាន លើការកែលំអប្រភពទិន្នន័យជញ្ជីងទូរទាត់ វិធីសាស្ត្រចងក្រង និង សង្គតិភាព ជាមួយនឹងសៀវភៅណែនាំបោះពុម្ពលើកទី៥ ស្តីពីជញ្ជីងទូរទាត់របស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ លើសពីនេះទៅទៀត ប្លង់គណនេយ្យថ្មីដែលស្របគ្នាទៅនឹងបទដ្ឋានអន្តរជាតិ ត្រូវបានដាក់អោយប្រើសំរាប់ធនាគារពាណិជ្ជទាំងឡាយ ដោយមានទាំងវិធីសាស្ត្រថ្មីសំរាប់ប្រមូលស្ថិតិអំពីរូបិយវត្ថុ និង ហិរញ្ញវត្ថុ [16] ។ ជាសង្ខេបបុគ្គលិករបស់ធនាគារជាតិមានសមត្ថភាពខ្ពស់ មានទំនាក់ទំនងទៅនឹងភាពជ្រួតជ្រាបខ្លាំងរបស់ជំនួយបច្ចេកទេសនៅក្នុងវិស័យនេះ ។

២០- ផ្ទុយទៅវិញ យើងពិនិត្យឃើញថាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្ថិតនៅចុងចំនុចម្ខាងទៀត ។ នៅក្នុងក្រសួងនេះបៀវត្សមានកំរិតទាបមែនទែន ហើយការតែងតាំងផ្អែកជាសំខាន់ទៅលើហេតុផលនយោបាយ ។ បដិបក្ខភាពផ្នែកនយោបាយនៅក្នុងក្រសួង បានធ្វើអោយរាំងស្ទះដល់កិច្ចសហប្រតិបត្តិការ និង ការសំរបសំរួលក្នុងចំណោមមន្ត្រី[17]។ ដូចនេះហើយអត្រាផ្ទេរចេញ/លះបង់ការងារខ្ពស់ មន្ត្រីមានជំនាញមានតិចតួច ហើយអ្នកជំនាញការបច្ចេកទេសពុំមានមន្ត្រីដែគួរធ្វើការពេញម៉ោង ។ មិនមានអ្វីគួរអោយភ្ញាក់ផ្អើលទេ ដែលថាជំនួយដើម្បីកែលំអស្ថិតិហិរញ្ញវត្ថុ

[14] ការផ្តល់ប្រឹក្សាទាំងនេះ ធ្វើឡើងដោយ ជំនាញការរយៈពេលវែង ដើម្បីធានាថាឥទ្ធិពលរបស់ជំនួយបច្ចេកទេស មិនបណ្តាលមក ពីការផ្លាស់ប្តូរជំនាញការ តែយ៉ាងណាក៏ដោយអ្នកជំនាញការទទួលស្គាល់ថា គាត់មានជំនាញខ្លាំងទៅលើ គណនេយ្យជាតិ និង ស្ថិតិជញ្ជីងទូទាត់។

[15] ភស្តុតាងសំរាប់ភាពខុសគ្នានេះគឺជាហេតុការណ៍ដែលកើតមាន។

[16] រាជរដ្ឋាភិបាលកម្ពុជា (២០០៣)

[17] ទៅតាមការពន្យល់ដោយជំនាញការជំនួយបច្ចេកទេស ប្រធាននាយកដ្ឋាននីមួយៗ នៃក្រសួងតែងតែបដិសេធ នឹងបំណងជួបគ្នា ដោយសារតែពួកគេឋិតនៅក្នុងគូរបដិបក្ខផ្នែកនយោបាយ សូម្បីនៅពេលដែលកិច្ចប្រជុំរៀបចំដោយជំនាញការ។

រដ្ឋាភិបាលបង្កើតជាឧបសគ្គជាច្រើន ដោយសារតែខ្វះមន្ត្រីជាដៃគូរធ្វើការពេញម៉ោងនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាពិសេសសំរាប់ស្ថិតិពីបំណុលរបស់រដ្ឋាភិបាល[18] ។

២១- ករណីល្អប្រសើរជាមធ្យមត្រូវបានពិនិត្យឃើញនៅវិទ្យាស្ថានជាតិស្ថិតិ ។ ដូចគ្នានៅក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្ថាប័ននេះមានបុគ្គលិកដែលមានបៀវត្សទាប និង ប្រឈមមុខយ៉ាងលំបាកក្នុងការរក្សាទុកមន្ត្រីដែល មានជំនាញ ។ តែទោះជាយ៉ាងណា មានចំនុចពិសេសមួយសំរាប់ស្ថាប័ននេះ គឺមិនមានបញ្ហាផ្នែកនយោបាយ ។ ផ្ទុយពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ថាប័ននេះមិនមានធនធានច្រើន ដូចនេះហើយមិនមែនជាចំណាប់អារម្មណ៍ របស់ក្រុមអ្នកនយោបាយឡើយ ។ ស្ថាប័ននេះមានថវិកាសមល្មម តែមានសេរីភាពផ្នែកនយោបាយយ៉ាងល្អ ។ និយាយម្យ៉ាងទៀត គឺថាមន្ត្រីនៃវិទ្យាស្ថានជាតិស្ថិតិមានការលំបាកនឹងទទួលបាននូវធនធាន ប៉ុន្តែពួកគេមាន ភាពទំនេរច្រើន ក្នុងន័យដែលថាពួកគេអាចធ្វើការងារផ្ទាល់ខ្លួនបាន ។ ជាលទ្ធផល ឥទ្ធិពលនៃជំនួយបច្ចេកទេសនៅ ក្នុងស្ថាប័ននេះមានឥទ្ធិពលជាង បើប្រៀបធៀបទៅនឹងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ភាពអាចរកបាន និង គុណភាពនៃប្រភពទិន្នន័យលើគណនីជាតិ តុល្យភាពជញ្ជីងទូទាត់ ហើយនឹងស្ថិតិសេដ្ឋកិច្ច-សង្គមដ៏ទៃទៀត ដែលមាននៅក្នុងសៀវភៅស្ថិតិប្រចាំឆ្នាំ មានភាពប្រសើរឡើង [19]។ វិទ្យាស្ថានជាតិស្ថិតិអាចផលិតដោយខ្លួនឯងបាន ជាសារវ័ន្តនូវទិន្នន័យពីគណនីជាតិ និង សន្ទស្សន៍ថ្លៃអ្នកប្រើប្រាស់។

២២- ជាសរុប ភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេសនៅគ្រប់ផ្នែកទាំងឡាយនៃស្ថិតិទទួលរងឥទ្ធិពលនៃគុណភាព និង ការិតនៃការរៀបចំស្ថាប័នរបស់ការិយាធិបតេយ្យនីមួយៗ ។ ធនាគាជាតិនៃកម្ពុជា បានរៀបចំស្ថាប័នដែលបំពេញ មុខងារបានល្អបំផុត ក៏ជាស្ថាប័នទទួលបានជោគជ័យជាងគេក្នុងការអនុវត្តន៍អនុសាសាន៍របស់ជំនួយបច្ចេកទេស ក្នុងខណៈដែលជំនួយបច្ចេកទេសនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភាពជ្រួតជ្រាបតិចតួចដោយសារតែការិត នៃការរៀបចំស្ថាប័ននៅមានភាពទន់ខ្សោយ ។ វិទ្យាស្ថានជាតិស្ថិតិជាករណីកណ្តាល [20]។ មេរៀនដ៏សំខាន់ដែលយើង អាចទាញយកពីបទពិសោធន៍នេះ គឺថា ដើម្បីអោយជំនួយបច្ចេកទេសមានការជ្រួតជ្រាបខ្លាំង និង យូរអង្វែងចាំបាច់ ត្រូវតែមានមន្ត្រីរាជការដែលមានការិតស្មេរភាពអាជីពអប្បរមា និង បៀវត្សប្រកួតប្រជែង ។

## ៤. កត្តាដែលស្ថិតក្រោមការគ្រប់គ្រងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

២៣- កត្តាកំណត់ដើម្បីអនុវត្តន៍កំណែទំរង់ និងគុណភាពនៃមន្ត្រីរាជការរបស់ប្រទេស ជាអថេរជាក់លាក់ដែលមិនឋិត នៅក្រោមការគ្រប់គ្រងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ ឥឡូវនេះ យើងនឹងផ្តោតការយកចិត្តទុកដាក់ទៅលើកត្តា ទាំងឡាយដែលមូលនិធិរូបិយវត្ថុអន្តរជាតិអាចគ្រប់គ្រងបាន ព្រមទាំងអាចជះឥទ្ធិពលទៅដល់ប្រសិទ្ធិភាពនៃជំនួយ បច្ចេកទេសនៅគ្រប់ដំណាក់កាល ពោលគឺគុណភាពនៃការធ្វើវិនិច្ឆ័យគំរោង ការសំរបសំរួល ការអនុវត្តន៍ ការបែង ចែកសេវា និង ការតាមដាន ។

---

[18] រាជរដ្ឋាភិបាលកម្ពុជា (២០០៣)

[19] សូមមើល រាជរដ្ឋាភិបាលកម្ពុជា (២០០៣)

[20] ឥទ្ធិពលអវិជ្ជមាននៃស្ថាប័នដែលបំពេញតួនាទីមិនល្អ មិនមែនតែលើការិតជំនួយបច្ចេកទេសផ្នែកស្ថិតិទេ ។ ឧទាហរណ៍ជំនួយ បច្ចេកទេសក្នុងការអនុវត្តន៍ថវិកា និង រតនាគារជាតិត្រូវបានជះឥទ្ធិពលគួរអោយកត់សំគាល់ដោយភាពខ្វះខាតនូវមន្ត្រីដៃគូរ ដែល មានសមត្ថភាព និង ធ្វើការងារពេញម៉ោង ។

## ក. ការធ្វើវិនិច្ឆ័យ និង ការសំរបសំរួល ក្រោមកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេសៈ ករណីសិក្សាអំពីជំនួយបច្ចេកទេសសំរាប់ការអនុវត្តន៍ថវិកា និង រតនាគារ

២៤ នៅកម្ពុជា កម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេសត្រូវបានជ្រើសរើសយកជាឧបករណ៍ ដើម្បីរកអោយឃើញនូវឧបសគ្គរាំងស្ទះដល់ការកសាងសមត្ថភាព និង បង្កើតឡើងផែនការសកម្មភាព ដើម្បីដោះស្រាយបញ្ហាទាំងនេះក្នុងចរិតជាប្រព័ន្ធ និង មានការសំរបសំរួល ។ សំរាប់រយៈពេលបួនឆ្នាំនៅក្នុងដំណើរការនេះ គេទទួលបាននូវចំណាប់អារម្មណ៍ចំរុះ ។ ក្នុងន័យមួយ គ្រប់អ្នកចូលរួម ឬ តួអង្គក្នុងជំនួយបច្ចេកទេសនេះ ចាប់តាំងពីអាជ្ញាធររដ្ឋាភិបាលដល់អ្នកផ្តល់ជំនួយ សុទ្ធតែបានទទួលស្គាល់ថា កម្មវិធីនេះជាជំហ៊ានអនុវត្តន៍ជាដំណាក់ៗ ឈានទៅរៀបចំក្របខ័ណ្ឌរយៈពេលមធ្យមសំរាប់ការផ្តល់ជំនួយបច្ចេកទេស ហើយព្យាយាមសំរបសំរួលម្ចាស់ជំនួយទាំងអស់ (ប្រអប់១) ។ តែម្យ៉ាងទៀត កម្មវិធីនេះគ្រាន់តែជាការដាក់បញ្ចូលគ្នារវាងគំនិតផ្តួចផ្តើមផ្សេងៗគ្នា តែមិនបានបង្កើតជាយុទ្ធសាស្ត្ររួមមួយសំរាប់ការកសាងសមត្ថភាពទេ ការអនុវត្តន៍សមាសភាគនីមួយៗ ផ្សេងៗគ្នា នៅតែមានលក្ខណៈដាច់ដោយឡែកៗ ។ ជាលទ្ធផល ឧបសគ្គចំពោះសមត្ថភាពជារឿយៗត្រូវបានលើកមកដោះស្រាយ ដោយពុំមានការសំរបសំរួលក្នុងចំណោមម្ចាស់ជំនួយឡើយ ។

**ប្រអប់ ១: កម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេសនៅកម្ពុជា**

ក្នុងទស្សនៈដែលថា កម្ពុជាមានសមត្ថភាពផ្នែកស្ថាប័នមានកំណត់ រាជរដ្ឋាភិបាលកម្ពុជាបានស្នើរអោយមានជំនួយពីមូលនិធិរូបិយវត្ថុអន្តរជាតិ ដើម្បីរៀបចំនូវកម្មវិធីទូលំទូលាយមួយស្តីពីជំនួយបច្ចេកទេសដែលគ្របដណ្តប់លើផ្នែកសំខាន់ៗនៃការកែទំរង់ និង គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ។ មកដល់ពេលចុងក្រោយនេះ ការពិភាក្សាជាបន្តបន្ទាប់រវាងរាជរដ្ឋាភិបាល មូលនិធិរូបិយវត្ថុអន្តរជាតិ និង កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ព្រមទាំងម្ចាស់ជំនួយពហុភាគី និងទ្វេភាគីជាច្រើនទៀត បានបង្កើតអោយមានកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស ហើយដាក់អោយអនុវត្តន៍ជាផ្លូវការនៅថ្ងៃទី ១ មិថុនា ឆ្នាំ ២០០១ ។ កម្មវិធីនេះជាកិច្ចប្រឹងប្រែងរួមគ្នា ដែលផ្តល់មូលនិធិដោយមូលនិធីផ្សេងៗគ្នា ជាពិសេសមូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ី ចក្រភពអង់គ្លេស ហូឡង់ និង កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ។ សមាសភាពជាសំខាន់នៃកម្មវិធីនេះមានៈ ក/ (១) កំណែទំរង់សារពើពន្ធ រួមបញ្ចូលទាំងការកែលំអរការគ្រប់គ្រងថវិកា ការពង្រីកមូលដ្ឋានពន្ធ ជៀសវាងការលើកលែងពន្ធពិសេសៗ និង កែលំអររដ្ឋបាលពន្ធដារ ។ (២) ការធ្វើវិចារណកម្មចំណាយរដ្ឋាភិបាលឡើងវិញ ទៅអោយកម្មវិធីអាទិភាពដូចជាកសិកម្ម អភិវឌ្ឍន៍ជនបទ សុខាភិបាល និង អប់រំ ។ (៣) ធ្វើកំណែទំរង់ប្រព័ន្ធធនាគារ និង ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា។ (៤) ធ្វើអោយប្រសើរឡើងនូវគុណភាព និងភាពទាន់ពេលវេលានូវទិន្នន័យហិរញ្ញវត្ថុ ។ (៥)កែលំអរនូវនិតិវិធីរដ្ឋបាល ដើម្បីធានាអោយបានការចំណាយទៅលើសង្គមទៅដល់គោលដៅដែលបានកំណត់ និង (៦) ធ្វើអោយប្រសើរឡើងនូវអភិបាលកិច្ច វិស័យសាធារណៈ តម្លាភាព គណនេយ្យភាព និង ប្រកាន់ខ្ជាប់នូវនិតិរដ្ឋ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាអ្នកទទួលខុសត្រូវលើ ការអនុវត្តន៍ និង ត្រួតពិនិត្យជាទូទៅនៃកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេសនេះ ដែលក្នុងនោះក្រសួងហិរញ្ញវត្ថុទទួលខុសត្រូវទៅលើការផ្តល់ជាទីប្រឹក្សាជាតិ ព្រមទាំងអ្នកជំនាញការរយៈពេលខ្លី នៅក្នុងផ្នែកសារពើពន្ធ ផ្នែកប្រព័ន្ធធនាគារស្ថិតិសេដ្ឋកិច្ច និង ផ្នែកច្បាប់។ តួនាទីនៃកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិមិនបានកំនត់ច្បាស់លាស់ ដែលនាំអោយមានការយល់ច្រឡំខ្លះ ។ ជាពិសេស កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ចាត់ទុកថាកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេសជាយន្តការដើម្បីពិភាក្សា ពីមាតិការគោលនយោបាយម៉ាក្រូនៃអនុសាសន៍ជំនួយបច្ចេកទេសក្នុងចំណោមដៃគូរទាំងឡាយ ចំណែកមូលនិធិរូបិយវត្ថុអន្តរជាតិ មើលឃើញថា កម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេសនេះជាយន្តការសំរបសំរួលហើយមិនមែនជាវេទិកាសំរាប់ពិភាក្សាគោលនយោបាយទេ ។ ដោយសារតែមានគោលបំណងនឹង សម្រប

| |
|---|
| សម្រួលនូវជំនួយបច្ចេកទេសផ្សេងៗគ្នា គណៈកម្មការអចិន្ត្រៃយ៍មួយ ត្រូវបានបង្កើតឡើងដោយមានការចូលរួមពីមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ សមាជិកនៃសហគមន៍អ្នកផ្តល់ជំនួយ និង ក្រោមអធិបតីភាព របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ តែទោះជាយ៉ាងណា នៅពេលដែលកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស ដំណើរការ គណកម្មការនេះបង្ហាញអោយឃើញភាពមិនគ្រប់គ្រាន់ ហើយអ្នកគ្រប់គ្រងគំរោងជាយថាហេតុបានលើកឡើងពីបញ្ហា កង្វះខាតការសំរបសំរួលដ៏មានប្រសិទ្ធិភាព ។ |
| ក/ រាជរដ្ឋាភិបាលកម្ពុជា «កម្ពុជាៈ កម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស» (២០០១)។ |

២៥- នៅក្នុងដំណាក់កាលធ្វើការវិនិច្ឆ័យ ការយល់អោយបានស៊ីជំរៅនូវបរិបទស្ថាប័នក្នុងស្រុកត្រូវតែយកចិត្តទុកដាក់ព្រមទាំងការពន្យល់អោយបានទូលំទូលាយដល់មន្ត្រីថ្នាក់កណ្តាល អោយបានយល់ច្បាស់ពីហេតុផលនៃអនុសាសន៍នីមួយៗ ។ សំរាប់កថាខ័ណ្ឌខាងក្រោម យើងនឹងលើកយកបទពិសោធន៍ជំនួយបច្ចេកទេសនៅក្នុងការអនុវត្តន៍ថវិកា និង រតនាគារ ដើម្បីពង្រីកមើលបញ្ហាទាំងនេះ ហើយទាញយកនូវមេរៀនសំខាន់ៗមួយចំនួន ។

២៦- ដំណើរការអនុវត្តន៍ថវិកានៅកម្ពុជា ត្រូវបានកំណត់ដោយកង្វះសាច់ប្រាក់ជាអន្លើៗ និង ការពន្យាពេលយូរដោយពុំមានការចាំបាច់ក្នុងការអនុម័តចំណាយ [21]។ នៅក្នុងបរិបទនេះ គោលបំណងដ៏សំខាន់នៃជំនួយបច្ចេកទេសនៅក្នុងផ្នែកនេះ គឺការអនុវត្តន៍សាកល្បងនូវប្រព័ន្ធអនុវត្តន៍ថវិកាដែលនឹងជំនួសគ្រប់ប្រព័ន្ធប្រតិបត្តិការហិរញ្ញវត្ថុនៅកម្ពុជាបច្ចុប្បន្នដែលមានលក្ខណៈដាច់កង់ៗ ។ ការសាកល្បងនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីបង្ហាញអំពីប្រយោជន៍នៃការធ្វើវិសហមជ្ឈការការត្រួតពិនិត្យហិរញ្ញវត្ថុ ។ ប៉ុន្តែការសាកល្បងនេះពុំបានទទួលជោគជ័យ ដោយសារតែវិបត្តិលំហូរសាច់ប្រាក់ជាប្រចាំ បណ្តាលមកពីស្តុកនៃបំណុលមិនទាន់ទូទាត់កើនឡើងច្រើនឡើងៗ ដែលប្រការនេះជាចំនុចក្តៅសំរាប់ការអនុវត្តន៍នៅក្នុងប្រព័ន្ធថវិការបស់កម្ពុជា ។ នៅកម្ពុជា ច្បាប់ថវិកាប្រចាំឆ្នាំពុំមានឥណទានថវិកាសំរាប់ដោះស្រាយបំណុលកកស្ទះមិនទាន់ទូទាត់ កើតមាននៅឆ្នាំថវិកាមុនៗ ពោលគឺបំណុលកកស្ទះចាស់ៗ ។ ដូច្នេះហើយចំណូលដែលទទួលបានក្នុងឆ្នាំបច្ចុប្បន្នសំរាប់ចំណាយក្នុងឆ្នាំបច្ចុប្បន្ន ត្រូវបានបង្វែរសំរាប់ទូទាត់បំណុលកកស្ទះវិញ រីឯការចំណាយក្នុងឆ្នាំបច្ចុប្បន្ន ត្រូវធ្វើឡើងដោយជំពាក់ ។ ដោយមានការបង្វែរបែបនេះជាបន្តបន្ទាប់បំណុលកើតមានជាដ៏រាបសំរាប់ឆ្នាំក្រោយៗ [22] ។ ប៉ុន្តែពីដំបូង វិសាលភាព និង ធម្មជាតិនៃបញ្ហាបំណុលកកស្ទះមិនទាន់ទូទាត់ នៅក្នុងការអនុវត្តន៍ថវិកា និង ការគ្រប់គ្រងសាច់ប្រាក់ មិនត្រូវបានគេកំណត់ច្បាស់នៅឡើយទេ ។ ប្រការនេះជាលទ្ធផលមិនអាចចៀសផុត សំរាប់ «បេសកម្មវិនិច្ឆ័យ» ដែលមានរយៈពេលខ្លី ដើម្បីស្វែងយល់បានច្បាស់ពីភាពស្មុគ្រស្មាញនៃយន្តការស្ថាប័នក្នុងផ្នែកថវិកានេះ ។ ឥទ្ធិពលរបស់ជំនួយបច្ចេកទេសនៅក្នុង ដំណាក់កាលដំបូងនេះក៏រងឥទ្ធិពលដោយសារតែភាពទន់ខ្សោយនៃការផ្តល់ទីប្រឹក្សាដំបូងលើសកម្មភាពនៅក្នុងផ្នែកនេះដែរ ។

២៧- សំរាប់រយៈពេលបន្តបន្ទាប់ទៀតមានការកែលំអរជាច្រើន ដើម្បីអាចអោយយល់ពីទំហំ និង ឫសគល់នៃបញ្ហាបំណុល និង សេចក្តីសន្និដ្ឋានទៅលើប្រព័ន្ធថវិកាទាំងមូល ។ ជាលទ្ធផល នីតិវិធីអនុវត្តន៍ថវិកាថ្មីត្រូវបានគេអនុវត្តន៍ហើយកំណែទំរង់រតនាគារត្រូវជុសខាត់បន្ថែមទៀត ។ វិសាលភាពនៃបញ្ហាបំណុលត្រូវបានយល់យ៉ាងពេញលេញហើយមានការផ្តោតការយកចិត្តទុកដាក់របស់គណៈកម្មការគ្រប់គ្រងសាច់ប្រាក់ ដោយបង្វែរពីតួនាទីអកម្មដែល

---

[21] មូលនិធិរូបិយវត្ថុអន្តរជាតិ «កម្ពុជាៈ យុទ្ធសាស្ត្រសារពើពន្ធសង្ខេប» (២០០៣)

[22] សូមមើល រាជរដ្ឋាភិបាលកម្ពុជា (២០០៣)

ព្យាយាមគ្រប់គ្រងវិបត្តិថវិកាតាមរយៈរបបកំណត់សាច់ប្រាក់នៅចុងបញ្ចប់នៃដំណើរការចំណាយ ទៅជាតួនាទីសកម្មចូលរួមដោយផ្តោតទៅលើការគ្រប់គ្រងការផ្តល់សិទ្ធិលើចំណាយ មុនពេលមានការអនុវត្តន៍ ។

២៨- បទពិសោធន៍ជាមួយនឹងការទូទាត់បំណុល អាចនឹងមានលទ្ធផលដែលមិនអាចជៀសផុតក្នុងរយៈពេលខ្លីសំរាប់បេសកម្មវិនិច្ឆ័យ ។ នៅប្រទេសដូចជាកម្ពុជា បេសកម្មវិនិច្ឆ័យត្រូវការរយៈពេលវែង ឬក៏កំរិតអប្បបរមាមួយ ពីព្រោះតែមានបញ្ហាប្រឈមមុខស្មុគ្រស្មាញ និង លក្ខណៈពិសេសនៃប្រទេស ។ ដូចនេះ វាមានភាពចាំបាច់ ដែលផែនការសកម្មភាពធ្វើឡើងលំអិត ដោយអ្នកជំនាញការរយៈពេលវែង ដោយមានដាក់បញ្ចូលនូវបញ្ហាផ្នែកស្ថាប័ន ។

២៩- អភិក្រមទូលំទូលាយមួយត្រូវអោយមានដើម្បីដោះស្រាយបញ្ហាកើនឡើងនូវបំណុល ជាមួយនឹងប្រសិទ្ធិភាពសំរបសំរួលក្នុងចំណោមម្ចាស់ជំនួយអន្តរជាតិ ។ ឧទាហរណ៍ មិនមានកិច្ចប្រជុំទៀតទាត់រវាងម្ចាស់ជំនួយ ទាក់ទិននឹងកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ជំនួយបច្ចេកទេសផ្តល់ដោយម្ចាស់ជំនួយនីមួយៗធ្វើតែឯកឯងដោយមិនមានទំនាក់ទំនងជាមួយអ្នកដ៏ទៃទៀត សូម្បីតែមានផ្នែកខ្លះទាក់ទងគ្នា ។ ទាំងនេះជាចំនុចរាំងស្ទះទៅដល់លទ្ធភាពដោះស្រាយការវិបត្តិខ្វះខាតសាច់ប្រាក់អោយបានទំលំទូលាយ ។

៣០- កង្វះខាតនូវការសំរបសំរួលរវាងអាជ្ញាធរ និង ម្ចាស់ជំនួយជាឧបសគ្គចំពោះការអនុវត្តន៍ជោគជ័យនៃជំនួយបច្ចេកទេស(ប្រអប់២) ។ ម្យ៉ាងវិញទៀត ដើម្បីដោះស្រាយជាមួយនឹងម្ចាស់ជំនួយផ្សេងៗគ្នាជាមួយនឹងនិតិវិធីរដ្ឋបាលដែលត្រូវអោយមាន បង្ករជាភាពស្មុគ្រស្មាញទៅដល់អាជ្ញាធរ ។ កង្វះខាតនូវការសំរបសំរួលក៏ជាឱកាសសំរាប់អាជ្ញាធរនឹងគេងយកការទទួលខុសត្រូវ ពីព្រោះពួកគេអាចនឹងប្រើប្រាស់ឱកាសនេះដើម្បីផ្តល់យោបល់ជំទាស់ប្រឆាំងទល់គ្នាទៅវិញទៅមក សំរាប់ការអនុវត្តន៍ជាប្រយោជន៍របស់ពួកគេ ។ និយាយម៉្យាងទៀតគឺថាវាមានសភាពលំបាកឡើងៗ ដើម្បីធានាថាអាជ្ញាធរនឹងដើរតាមអនុសាសន៍របស់មូលនិធិរូបិយវត្ថុអន្តរជាតិនៅពេលដែលការផ្តល់ប្រឹក្សាដោយស្ថាប័នផ្សេងទៀតមិនមានសង្គតិភាពនឹងគ្នា ។ ជារួម ការសំរបសំរួលអោយតឹងតែងក្នុងចំណោមម្ចាស់ជំនួយធ្វើអោយ អាជ្ញាធរមានភាពងាយស្រួលច្រើន ហើយលុបបំបាត់នូវលេសនៅពេលដែលមិនមានលទ្ធផល។

**ប្រអប់ ២. ការសំរបសំរួលរវាងម្ចាស់ជំនួយ**

បន្ទាប់ពីមានបទពិសោធន៍ជាបន្តបន្ទាប់ពីកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស រដ្ឋាភិបាលកម្ពុជាជាមួយនឹងម្ចាស់ជំនួយអន្តរជាតិខ្លះ (មូលនិធិរូបិយវត្ថុអន្តរជាតិមានភាពស្ទាក់ស្ទើរក្នុងការចូលរួម) បានបង្កើតអោយមានអភិក្រមគ្របដណ្តប់លើវិស័យទាំងមូល ។ អភិក្រមនេះមានគោលបំណងនឹងផ្តល់អោយនូវអភិក្រមដែលមានលក្ខណៈដោះស្រាយបញ្ហាទាំងមូល និង មានការសំរបសំរួលល្អជាងមុនក្នុងការកសាងសមត្ថភាព និង បង្កើនភាពម្ចាស់ការ ដោយបង្ហាញអោយឃើញនូវតួនាទីនាំមុខរបស់អាជ្ញាធរ។ ជាពិសេស សំរាប់ស្ថានភាពស្ថាប័នដែលមានចំណុចរសើបច្រើន និង ផ្តល់អោយនូវទស្សនៈទូលំទូលាយពីតំរូវការជំនួយ ដោយមានការសំរបសំរួលដោយតឹងតែងរវាងម្ចាស់ជំនួយ និងអាជ្ញាធរ។ ផ្ទុយពីអ្វីដែលមាននៅក្នុងកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស អភិក្រមគ្របដណ្តប់លើវិស័យទាំងមូលផ្តោតទៅលើការពិភាក្សានិងកិច្ចព្រមព្រៀងនៅដំណាក់កាលវិនិច្ឆ័យ និង រៀបចំ ។ ការកាត់សេចក្តីថា តើអភិក្រមនេះទទួលបានជោគជ័យជាងកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស ហាក់ដូចជាឆាប់រហ័សពេក ប៉ុន្តែបង្ករអោយមានភាពតានតឹងរវាងការពង្រឹងភាពម្ចាស់ការ និង ប្រសិទ្ធភាពពេលវេលា ។ ម៉្យាងវិញទៀត ការព្យាយាមច្រើនពេកក្នុងការសំរេចអោយបានការមូលមតិគ្នា និង ការសំរបសំរួលអាចនាំមកនូវអំរែកបន្ថែមទៀត ចំពោះការអនុវត្តន៍អោយមានប្រសិទ្ធភាពនូវកំណែទំរង់ជំនួយបច្ចេកទេស ។

៣១- មេរៀនចុងក្រោយដែលអាចទទួលបានពីបទពិសោធន៍អនុវត្តន៍ថវិកា គឺថាដើម្បីធ្វើអោយប្រសើរនូវភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេស គេមិនអាចសន្មតពីវត្តមានស្រាប់នៃតួនាទីកិរិយាធិបតេយ្យបានទេ ។ ជាពិសេស កម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេសបានសន្មតថា មានច្រកទាក់ទងរវាងមន្ត្រីមានឋានៈខ្ពស់ និង មន្ត្រីថ្នាក់កណ្តាលដែលទទួលខុសត្រូវក្នុងការអនុវត្តន៍គំរោងហើយការសន្និដ្ឋាននេះបង្ហាញថាមិនត្រឹមត្រូវទេ ។ នៅពេលកម្មវិធីជំនួយបច្ចេកទេសដំបូងត្រូវបានអនុវត្តមូលនិធិរូបិយវត្ថុអន្តរជាតិ ផ្តោតទៅលើទំនាក់ទំនងរបស់ខ្លួនជាមួយស្ថាប័ននានា នៅកំរិតថ្នាក់ខ្ពស់ដោយសន្និដ្ឋានថា ពត៌មាននឹងត្រូវបញ្ជូនបន្តទៅមន្ត្រីថ្នាក់កណ្តាល ។ ប៉ុន្តែ ទំនាក់ទំនងខ្សែបណ្តោយនៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បង្ហាញថាមានភាពទន់ខ្សោយ ជាលទ្ធផលការរៀបចំកម្មវិធីចុងក្រោយដោយមិនមាន ការចូលរួមពីមន្ត្រីដែលទទួលខុសត្រូវអនុវត្តន៍គំរោងនេះទេ ដែលធ្វើអោយបាត់នូវភាពម្ចាស់ការរបស់គេយ៉ាងច្រើន ។ ឧទាហរណ៍មួយនៃបញ្ហានេះគឺ ករណីលោកអនុប្រធាននាយកដ្ឋានថវិកានិងហិរញ្ញកិច្ច ដែលមិនបានចូលរួមពិភាក្សាណាមួយក្នុងពេលធ្វើការវិនិច្ឆ័យ និង រៀបចំកម្មវិធី ហើយក្រោយមកទទួលខុសត្រូវអនុវត្តអនុសាសន៍ទាំងនោះ ។ មន្ត្រីរូបនេះមានការភ្ញាក់ផ្អើលដោយដឹងថា អាទិភាពរបស់កម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេសមិនបានជាប់ ពាក់ព័ន្ធនឹងអ្វីដែលគាត់គិតថាកម្មវិធីនោះគួរត្រូវអនុវត្ត ។ ឧទាហរណ៍ គាត់ពេញចិត្តការពង្រឹងប្រព័ន្ធថវិកាដែលមាន ស្រាប់ជាជាងប្តូរទៅជាអ្វីដែលគាត់គិតថាប្រព័ន្ធថវិកាទំនើប (state-of-the-art budget) ។ ដោយមិនគិតថា តើការព្រួយបារម្ភណ៍របស់គាត់ត្រូវឬអត់នោះទេ ការពិតគឺថាគាត់មិនមានឱកាសបញ្ចេញទស្សនៈរបស់គាត់ ដែលបាន បន្ថយការគាំទ្ររបស់គាត់សំរាប់ការអនុវត្តន៍ជំនួយបច្ចេកទេសនេះ ដែលយ៉ាងហោចណាស់នៅពេលចាប់ផ្តើមដំបូង ។ ប្រសិនបើមូលនិធិរូបិយវត្ថុអន្តរជាតិសកម្មចូលរួមអោយកាន់តែល្អប្រសើរជាមួយមន្ត្រីថ្នាក់កណ្តាល ក្នុងការពន្យល់ពីហេតុផលសំរាប់កំណែទំរង់ដែលបានស្នើឡើង សូម្បីតែកិច្ចការនេះត្រូវធ្វើដោយមន្ត្រីជាន់ខ្ពស់ក្តី ភាពម្ចាស់ការលើជំនួយបច្ចេកទេសអាចត្រូវបានបង្កើនជាមួយនឹងឥទ្ធិពលរបស់វាផងដែរ ។ ជារួម យុទ្ធសាស្រ្តងាយស្រួលដើម្បីបង្កើនជាអតិបរិមានូវភាពជ្រួតជ្រាបនៃអនុសាសន៍ជំនួយបច្ចេកទេស គឺត្រូវធានាថាមន្ត្រីទទួលបន្ទុកអនុវត្តគំរោងត្រូវបានគេផ្តល់ពត៌មានគ្រប់គ្រាន់ជាមុន ទោះបីមានទំនាក់ទំនងពិបាកក្នុងក្រសួងនីមួយៗនោះក្តី ។

៣២ ជាសរុប ការត្រួតពិនិត្យជំនួយបច្ចេកទេសក្នុងផ្នែកប្រតិបត្តិការថវិកាបានផ្តល់ជាមេរៀនសំរាប់ជំនួយបច្ចេកទេសដូចខាងក្រោម:

- កែលំអរកិច្ចសំរបសំរួលក្នុងចំណោមម្ចាស់ផ្តល់ជំនួយ គឺជាការចាំបាច់ មិនត្រឹមតែដើម្បីសំរួលដល់អភិក្រមមានចរិតជាប្រព័ន្ធទាំងមូល ប៉ុន្តែជៀសវាងបាននូវបន្ទុករដ្ឋបាលលើសលុប និង ជាលេសនៃកង្វះខាតលទ្ធផល ។

- បេសសកម្មធ្វើវិនិច្ឆ័យសំរាប់រយៈពេលយូរ ឬ ក្នុងកំរិតអប្បបរមាមួយ ហាក់ដូចជាល្អ សំរាប់ប្រទេសដូចជាកម្ពុជា ជាពិសេសសំរាបវិស័យដូចជាស្ថាប័នអនុវត្តថវិកា ដែលមានការប្រែប្រួលយ៉ាងខ្លាំងទៅតាមប្រទេសនីមួយៗ ។ នេះគឺជាករណីមួយ ពីព្រោះក្រុមបេសសកម្មរយៈពេលខ្លីអាចមិនមានពេលគ្រប់គ្រាន់ ដើម្បីស្វែងយល់អោយពេញលេញ ពីលក្ខណៈពិសេសរបស់ស្ថាប័ននៃប្រទេសនីមួយៗទេ ។

- ដើម្បីលើកកំពស់ភាពម្ចាស់ការ ចាំបាច់ត្រូវធានាអោយប្រាកដថាមន្ត្រីទាំងអស់ ជាពិសេសមន្ត្រីទទួលខុសត្រូវអនុវត្តគំរោងបានយល់ដឹងជាមុនពីហេតុផលនៃអនុសាសន៍ដែលបានលើកឡើង ។ ការងារនេះ គឺជាបញ្ហាប្រឈមជាចំបង និង មានសារៈសំខាន់ ក្នុងខណៈដែលទំនាក់ទំនងផ្ទៃក្នុងក្រសួងមិនមានលក្ខណៈគ្រប់គ្រាន់ ។

## គ. ទីប្រឹក្សារយៈពេលខ្លី និង រយៈពេលវែងៈ វដ្តជំនួយបច្ចេកទេស

៣៣- ភាគច្រើនលើសលប់ [23]នៃជំនួយបច្ចេកទេសត្រូវបានផ្តល់តាមរយៈទីប្រឹក្សារយៈពេលវែង ចំពោះមុខឧបសគ្គផ្នែកសមត្ថភាពដែលប្រទេសនេះកំពុងប្រឈម គឺជាមធ្យោបាយចាំបាច់បំផុត ។ ទីប្រឹក្សារយៈពេលវែងមិនត្រឹមតែបានបណ្តុះបណ្តាលមន្ត្រីដៃគូរបស់ខ្លួន ប៉ុន្តែត្រូវដើរតួនាទីជាសំខាន់ក្នុងការសំរបសំរួលក្នុងក្រសួង បើសិនជាជំនាញគ្រប់គ្រងនៃអាជ្ញាធរកម្ពុជាមានភាពទន់ខ្សោយ ។ នៅកំរិតបច្ចេកទេសថ្នាក់ទាបដែលជំនាញការបានជួបប្រទះ ដែលមិនអាចជៀសផុត គឺការតាមដានអោយបានជិតស្និទ្ធនូវការអនុវត្តន៍អនុសាសន៍នៃជំនួយបច្ចេកទេស និង កិច្ចដំណើរការរៀនសូត្ររបស់មន្ត្រីដៃគូរបស់ខ្លួន ។ លើសពីនេះទៀត នៅកន្លែងខ្លះដែលសមត្ថភាពគ្រប់គ្រងរបស់មន្ត្រីថ្នាក់ខ្ពស់ មិនមានបង្ហំអោយជំនាញការដោះស្រាយ មិនគ្រាន់តែទៅលើទស្សនៈបច្ចេកទេសទេថែមទាំងបង្រៀនអាជ្ញាធរទាំងនោះនូវគោលការណ៍គ្រប់គ្រងជាមូលដ្ឋានខ្លះ ។ ដោយសារតែភាពស្មុគស្មាញនៃស្ថាប័ននៅកម្ពុជា ជំនាញការរយៈពេលវែងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការទទួលអនុវត្តអនុសាសន៍នៃជំនួយបច្ចេកទេសដែលរៀបចំដោយក្រុមបេសកម្មវិនិច្ឆ័យរយៈពេលខ្លី [24]។ ជាទូទៅ យើងអាចសន្និដ្ឋានដោយយុត្តិធម៌ថា ប្រសិនបើគ្មានវត្តមានជំនាញការរយៈពេលវែងទេ ស្ថាប័នទាំងឡាយទំនងជាប្រឈមជាមួយបញ្ហាជាច្រើនលើសលប់ក្នុងការអនុវត្តន៍អនុសាសន៍នៃជំនួយបច្ចេកទេសភាគច្រើន ។

៣៤- ទោះបីជាយ៉ាងណាក៏ដោយ មានគ្រោះថ្នាក់ខ្លះៗក្នុងការប្រើជំនាញការរយៈពេលវែង ហើយពេលខ្លះគ្រោះថ្នាក់ទាំងនោះ ត្រូវបានគេលើកមកពិភាក្សានៅក្នុងមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ការពិនិត្យពិចារណានោះបានឈានដល់គោលនយោបាយផ្នែកស្ថាប័នមួយ ដែលគាំទ្រដល់ក្រុមបេសកម្មរយៈពេលខ្លីជាជាងជំនាញការរយៈពេលវែង[25] ។ ការព្រួយបារម្ភណ៍ជាពិសេសគឺគ្រោះថ្នាក់ដែលជំនាញការរយៈពេលវែង ក្លាយជាអ្នកគ្រប់គ្រងតាមខ្សែបណ្តោយ ។ នៅពេលបញ្ហានេះកើតមានឡើង គោលបំណងជាចំបងនៃការផ្ទេរចំណេះដឹងរបស់ជំនាញការ មានទំនោរទៅរកការអនុវត្តន៍សកម្មភាពការងារប្រចាំថ្ងៃដែលត្រូវធ្វើដោយមន្ត្រីនៅក្នុងក្រសួងនោះ ។ កិច្ចការទាំងនោះ មានដូចជាការសរសេរសុន្ទរកថា ការផ្តល់យោបល់ដល់រដ្ឋមន្ត្រី ឬ ការធ្វើការងារប្រចាំថ្ងៃដែលជំនាញការ មានកាតព្វកិច្ចត្រូវបង្រៀន គឺជាគ្រោះថ្នាក់ពិតប្រាកដ ដែលជះឥទ្ធិពលមិនល្អដល់ការកសាងសមត្ថភាពរបស់កម្មវិធីជំនួយបច្ចេកទេស ។ នៅក្នុង ប្រទេសមួយដែលមានមន្ត្រីបំរើការងារមានជំនាញទាប អ្នកគ្រប់គ្រងមានចំណូលចិត្តច្រើនក្នុងការប្រើប្រាស់ចំណេះដឹងរបស់ជំនាញការ សំរាប់ធ្វើការងារជាច្រើន ជាជាងគ្រាន់តែពាក់ព័ន្ធលើការផ្ទេរចំណេះដឹង ។ ជាថ្មីម្តងទៀត កម្ពុជាបានផ្តល់នូវពិសោធន៍សំខាន់ៗជាច្រើនលើរឿងនេះ ។

៣៥- ជំនាញការជំនួយបច្ចេកទេសរយៈពេលវែងទាំងអស់ ដែលក្រុមវាយតំលៃបានជួបពិភាក្សាបានទទួលស្គាល់ថានៅត្រង់ចំនុចខ្លះពួកគេបានជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការប្រចាំថ្ងៃរបស់នាយកដ្ឋាន និងមិនត្រឹមតែក្នុងការផ្ទេរចំណេះ

---

[23] ជាមធ្យម ៩៥ភាគរយនៃជំនួយបច្ចេកទេសទាំងអស់ដែលទទួលបានដោយកម្ពុជារវាងឆ្នាំ ១៩៩៤-២០០៤ ត្រូវបានបែងចែកអោយដោយជំនាញការប្រចាំស្រុករយៈពេលវែង។

[24] សូមមើលករណីដែលរៀបរាប់ខាងលើក្នុងករណីសិក្សាពីកំណែទំរង់ប្រតិបត្តិការថវិកា។

[25] សូមមើល IMF, "Review of Technical Assistance Policy and Experience" (2000) និង IMF, "Review of Technical Assistance evaluation Program—Findings of Evaluation and Updated Program" (2004)

ដឹងនោះទេ ។ ជាដំបូង លក្ខណៈបែបនេះហាក់ដូចជាបញ្ជាក់ច្បាស់ពីការព្រួយបារម្ភណ៍ដែលជំរុញអោយមានការផ្លាស់ប្តូរជំនាញការរយៈពេលវែង ។ ប៉ុន្តែមានកត្តាពីរត្រូវពិចារណាមុនពេលឈានដល់ការសន្និដ្ឋានណាមួយ ។ (ទី១) ការប្រតិបត្តិ «ការងារប្រចាំថ្ងៃ» ដែលអនុវត្តដោយជំនាញការ ហាក់ដូចជាបង្កើនភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេស ។ ឧទាហរណ៍ ជំនាញការស្ថិតិពហុវិស័យជាញឹកញាប់បានជួយដល់ការគ្រប់គ្រងវិទ្យាស្ថានជាតិស្ថិតិដើម្បីរៀបចំ និង កែលំអសំណើស្នើសុំជំនួយដើម្បីទទួលបាននូវធនធានចាំបាច់ដើម្បីអនុវត្តអនុសាសន៍នៃជំនួយបច្ចេកទេស ។ តាមរយៈមធ្យោបាយបែបនេះ វិទ្យាស្ថានជាតិស្ថិតិបានទទួលមូលនិធិពីអង្គការអន្តរជាតិមិនមែនរដ្ឋាភិបាល ដែលអាចអោយខ្លួន អាចអនុវត្តអនុសាសន៍នៃជំនួយបច្ចេកទេស ។ ជំនាញការទាំងនោះបានលើកឡើងផងដែរថា ការចូលរួមម្តងម្កាលក្នុងសកម្មភាពដែលមិនមានការពាក់ព័ន្ធនឹងជំនួយបច្ចេកទេស ដូចជាជួយសរសេរសុន្ទរកថា គឺមិនប្រើប្រាស់ពេលច្រើនណាស់ណាទេ ប៉ុន្តែបានជួយកែលំអទំនាក់ទំនងជាមួយអាជ្ញាធរ ដូចនេះធ្វើអោយមានការសហការល្អ។ នៅក្រោម កាលៈទេសៈខ្លះការពាក់ព័ន្ធដោយចេតនារបស់អ្នកជំនាញការក្នុងប្រតិបត្តិការប្រចាំថ្ងៃដើម្បីធ្វើអោយមានភាពជ្រួតជ្រាបប្រសើរឡើងនៃជំនួយបច្ចេកទេស យ៉ាងហោចណាស់ សកម្មភាពទាំងនោះអាចជួយទទួលបានការជឿជាក់ពីស្ថាប័ន ។

៣៦- ទន្ទឹមគ្នានោះដែរ អ្នកជំនាញការជំនួយបច្ចេកទេសរយៈពេលវែង បានលើកឡើងពីសំពាធក្នុងការបំពេញកិច្ចការប្រចាំថ្ងៃ ។ ពួកគេទទួលស្គាល់ផងដែរថា ពួកគេអាចបដិសេធចំពោះសំណើម្តងម្កាលទៅលើកិច្ចការទាំងឡាយដែលគួរតែអនុវត្តដោយមន្ត្រីជាដៃគូរនោះ ។ ពិតប្រាកដណាស់ អ្នកជំនាញការភាគច្រើនមានពេលខ្លះបានបដិសេធមិនពាក់ព័ន្ធសកម្មភាពដែលគេគិតថាមិនស្ថិតក្រោមអាណត្តិរបស់គេ និង អាជ្ញាធរក៏ស្រុះស្រួលទៅតាមនោះដែរ ។ អាស្រ័យហេតុនេះ ច្បាស់ណាស់ថា ទោះបីជាអ្នកជំនាញការរយៈពេលវែងប្រឈមនឹងគ្រោះថ្នាក់ក្លាយខ្លួនជាអ្នកគ្រប់គ្រងខ្សែបណ្តោយ ក៏រឿងនេះស្ថិតនៅលើពួកគេផ្ទាល់ ក្នុងការប្រកាន់ខ្ជាប់នូវការងារផ្ទេរចំណេះដឹង និង កសាងសមត្ថភាព ។ ម៉្យាងវិញទៀត គ្រោះថ្នាក់របស់ជំនាញការរយៈពេលវែងដែលត្រូវបានជ្រើសរើស រួមជាមួយនឹងការងារប្រចាំថ្ងៃ គឺជាការពិត ប៉ុន្តែស្ថិតក្រោមការគ្រប់គ្រងរបស់ពួកគេ ។ ក្នុងន័យនេះ ការប្រើប្រាស់អ្នកជំនាញការរយៈពេលវែងក្នុងប្រទេសមួយ ដូចជានៅកម្ពុជា ហាក់ដូចជាគ្រប់គ្រាន់ ។

៣៧- គ្រោះថ្នាក់របស់អ្នកជំនាញការរយៈពេលវែងដែលក្លាយជាអ្នកគ្រប់គ្រងតាមខ្សែបណ្តោយ គឺពាក់ព័ន្ធនឹងបញ្ហាថាតើល័ក្ខខ័ណ្ឌការងារពិស្តារគួតែថែងយ៉ាងដូចម្តេច ។ ប្រសិនបើលក្ខខ័ណ្ឌការងារគ្រប់គ្រាន់ច្បាស់លាស់ គ្រោះថ្នាក់សំរាប់ជំនាញការរយៈពេលវែងដែលពាក់ព័ន្ធនឹងប្រតិបត្តិការប្រចាំថ្ងៃនឹងត្រូវកាត់បន្ថយ ។ ម៉្យាងវិញទៀត ប្រសិនបើលក្ខ័ណ្ឌការងារបញ្ជាក់ច្បាស់លាស់ពេក មានគ្រោះថ្នាក់ក្នុងការបំភ្លេចចោលសេចក្តីត្រូវការសារៈសំខាន់ដែលមិនបានវិនិច្ឆ័យរកឃើញនៅពេលដំបូង ប៉ុន្តែហាក់បីដូចជាលេចឡើងច្បាស់លាស់នៅពេលកម្មវិធីមានភាពជឿនលឿន ។ ករណីមួយនៃការកែទំរង់ថវិកា គឺជាឧទាហរណ៍ល្អមួយដែលលក្ខខ័ណ្ឌការងារពីដំបូងរបស់ជំនាញការថវិកាលែងប្រើប្រាស់បានយ៉ាងរហ័ស ពីព្រោះតែកើតមាននូវសេចក្តីត្រូវការមិនបានគ្រោងទុក ។ នៅចុងបញ្ចប់ កិច្ចការរបស់ជំនាញការភាគច្រើនស្ថិតនៅក្រៅពីទំហំល័ក្ខខ័ណ្ឌការងារពីដំបូងរបស់គាត់ ។ សរុបមក មានភាពប្រទាញប្រទង់គ្នារវាងភាពជាក់លាក់ និង ភាពទន់ភ្លន់នៅពេលរៀបចំសេចក្តីព្រាងលក្ខខ័ណ្ឌការងារដែលចាំបាច់ត្រូវគេទទួលស្គាល់ ។ ល័ក្ខខ័ណ្ឌការងារជាក់លាក់ និង តូចចង្អៀត កាត់បន្ថយនូវគ្រោះថ្នាក់សំរាប់ជំនាញការដែលអាចក្លាយជា អ្នកគ្រប់គ្រងតាមខ្សែបណ្តោយ តែត្រូវចំណាយនូវភាពទន់ភ្លន់ក្នុងការផ្លាស់ប្តូរតបនឹងសេចក្តីត្រូវការដែលមិនបានគ្រោងទុក ។

៣៨- គ្រោះថ្នាក់មួយនៃការប្រើប្រាស់យ៉ាងទូលំទូលាយនូវជំនាញការរយៈពេលវែង គឺថាអាជ្ញាធរអាចពឿន នឹងជំនួយបច្ចេកទេស ។ គ្រោះថ្នាក់នេះ ហាក់ដូចជាកើតមានបច្ចុប្បន្ន ជាពិសេសនៅធនាគារជាតិនៃកម្ពុជា ។ ស្ថាប័ននេះ បានទទួលជោគជ័យយ៉ាងធំធេងក្នុងការអនុវត្តន៍អនុសាសន៍ជំនួយបច្ចេកទេស និង ក្នុងការបណ្តុះបណ្តាលមន្ត្រីរបស់ខ្លួន ។ ក្នុងន័យគោរព ធនាគារជាតិនៃកម្ពុជា គឺជា«កូនសិស្ស»ដ៏ល្អនៃជំនួយបច្ចេកទេស ប៉ុន្តែទោះបីជាសមត្ថភាពរបស់មន្ត្រីរបស់ខ្លួនកើនឡើងក៏មន្ត្រីមួយចំនួននៅធនាគារជាតិនៃកម្ពុជា មានភាពស្ទាក់ស្ទើរក្នុងការផ្សងព្រេងនឹងធ្វើកិច្ចការថ្មីៗ បើសិនជាពុំមានគោលការណ៍ណែនាំនៃជំនួយបច្ចេកទេសរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ ។ ធនាគារជាតិនៃកម្ពុជា គឺជាកូនសិស្សដ៏ល្អ ប៉ុន្តែគ្មានបំណងចាប់ផ្តើមអនុវត្តការងារដោយខ្លួនឯងឡើយ ។ ដូច្នេះទោះបីជា ទទួលជោគជ័យក្នុងការកសាងសមត្ថភាព ភាពទោរទន់ទៅលើជំនួយបច្ចេកទេសមិនបានកាត់បន្ថយនៅឡើយទេ ។

៣៩- បទពិសោធន៍នេះ បានលើកឡើងពីតំរូវការអោយមានការរៀបចំផែនការជាមុនថា តើត្រូវដកចេញនូវជំនួយបច្ចេកទេសដូចម្តេច ដើម្បីជំរុញអាជ្ញាធរក្នុងស្រុកចាប់ផ្តើមអនុវត្តការងារដោយខ្លួនឯង និង ជួយពួកគេអោយបានបញ្ចប់ការសិក្សា ។ លទ្ធភាពមួយគឺត្រូវផ្លាស់ប្តូរពីជំនាញការរយៈពេលវែងទៅជា ជំនាញការបង្រៀនអោយដើរនៅពេលដែលសមត្ថភាពត្រូវបានពង្រឹងប្រកបដោយជោគជ័យនៅក្នុងកំរិតជាក់លាក់មួយ ។ ឧទាហរណ៍ នៅកម្ពុជា ធនាគារជាតិនៃកម្ពុជា ហាក់ដូចជាសំរេចបាននូវដំណាក់កាលមួយដែលជំនាញការរយៈពេលវែងលែងមានសារៈសំខាន់ និង ត្រូវការផ្លាស់ប្តូរទៅរកជំនាញការបង្រៀនដើរ មានលក្ខណៈសមស្រប និង ប្រសើរជាង ។ ការផ្លាស់ប្តូរទៅជាជំនាញការបង្រៀនដើរនេះ មិនធ្វើអោយរាំងស្ទះដល់ដំណើរសិក្សា និង ការកសាងសមត្ថភាពទេ តែស្របពេលជាមួយគ្នានេះដែរវាជំរុញអោយអាជ្ញាធរពឹងពាក់លើខ្លួនឯងកាន់តែច្រើនឡើងនឹងបង្កើនកំរិតជំនាញរបស់ខ្លួន ។ ការផ្លាស់ប្តូរនេះ អាចត្រូវធ្វើអោយរលូនដោយបញ្ជូនមន្ត្រីកាន់តែច្រើន ទៅបណ្តុះបណ្តាលនៅសិក្ខាសាលានៅក្រៅប្រទេស ។ ជាចុងក្រោយ ដំណើរការកសាងសមត្ថភាពបន្តរផ្លាស់ប្តូរពីជំនាញការដើរបង្រៀន ទៅជាក្រុមបេសសកម្មរយៈពេលខ្លី ។

៤០- បញ្ហាចុងក្រោយ ដែលនឹងត្រូវចាប់អារម្មណ៍ គឺជាលក្ខណៈសម្បត្តិរបស់អ្នកជំនាញរយៈពេលវែង។ អាជ្ញាធរភាគច្រើនបានបង្ហាញពីចំណូលចិត្តខ្លាំងទៅលើអ្នកជំនាញការធ្វើការច្រើនយ៉ាង (hand-ons) ដែលចង់ធ្វើការជិតស្និទ្ធជាមួយមន្ត្រីដៃគូ ។ មន្ត្រីរាជការមកពីក្រសួងផ្សេងៗ ដូចជា វិទ្យាស្ថានជាតិស្ថិតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬ ធនាគារជាតិនៃកម្ពុជា សរសើរអ្នកជំនាញការដែលអង្គុយជាមួយពួកគាត់នៅមុខកុំព្យូទ័រដើម្បីបង្រៀន និង ជួយដល់មន្ត្រីដៃគូរក្នុងស្រុក។ អ្នកជំនាញការធ្វើការច្រើនយ៉ាង ទទួលបានជោគជ័យច្រើនក្នុងការផ្ទេរចំណេះដឹង ។ មេរៀនមួយទៀតដែលអាចយកចេញមកពីបទពិសោធន៍របស់កម្ពុជា គឺ ភាពងាយស្រួលនឹងមានអ្នកជំនាញការ ដែលស៊ាំនឹងការងារករិយាធិបតេយ្យ ។ នៅពេលដែលអ្នកជំនាញធ្លាប់ជាមន្ត្រីរាជការ ពួកគេដូចជាមានជោគជ័យច្រើនក្នុងការបញ្ជូនសាររបស់ពួកគេទៅកាន់អាជ្ញាធររដ្ឋាភិបាល។ ឧទាហរណ៍ ការបង្ហាញដោយសង្ខេបហើយច្បាស់លាស់ប្រសើរជាងរបាយការណ៍វែងសំរាប់អោយអ្នកធ្វើការសំរេចចិត្ត បង្កើនលទ្ធភាពទៅរកដំណោះស្រាយឆាប់រហ័ស និង ល្អប្រសើរ ។ ចរិកលក្ខណៈនៃអ្នកជំនាញការរយៈពេលវែងដែលគេចង់បាន គឺមានរួមផ្សំគ្នារវាងជំនាញគ្រប់គ្រង និងសមត្ថភាពធ្វើការរៀបចំផែនការយុទ្ធសាស្ត្រ ។ ការផ្តល់ទៅអោយអាជ្ញាធរដែលមិនសូវមានជំនាញគ្រប់គ្រងនូវអ្នក

ជំនាញរយៈពេលវែងជាញឹកញាប់ត្រូវសម្របសម្រួល និង រៀបចំផែនការសំរាប់សកម្មភាពនាពេលអនាគត ដូច្នេះហើយតំរូវអោយមានអ្នកជំនាញដែលមានបទពិសោធន៍ខាងគ្រប់គ្រង ។ បទពិសោធន៍ខុសគ្នា របស់អ្នកជំនាញប្រចាំក្នុងការប្រតិបត្តិថវិកា និង រតនាគារ ក៏បង្ហាញអោយឃើញផងដែរនូវលក្ខណៈវិនិច្ឆ័យសំខាន់ដទៃទៀត ដូចជាចំណេះដឹងបច្ចេកទេសស៊ីជំរៅ និង សមត្ថភាពធ្វើការជិតស្និតជាមួយ ទាំងអាជ្ញាធរនយោបាយ និង បច្ចេកទេស ។ សរុបមក ជំនាញគ្រប់គ្រងលើការងារច្រើនយ៉ាង បទពិសោធន៍នឹងការិយាធិបតេយ្យ ចំណេះដឹងបច្ចេកទេសស៊ីជំរៅ និង សមត្ថភាពធ្វើការជិតស្និទ្ធជាមួយទាំងអាជ្ញាធរនយោបាយ និង បច្ចេកទេស គឺជាលក្ខណៈសម្បត្តិរបស់អ្នកជំនាញការរយៈពេលវែង ដែលធ្វើអោយប្រសើរឡើងនូវភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេសនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប ។

## គ. ការអនុវត្តន៍: កង្វះខាតធនធាន

៤១- បញ្ហាដែលអាជ្ញាធរលើកឡើងជាញឹកញាប់ គឺកង្វះខាតធនធាន ដើម្បីអនុវត្តអនុសាសន៍ជំនួយបច្ចេកទេស ។ ឧទាហរណ៍សំខាន់នៃភាពខ្វះខាតនេះ គឺ កង្វះខាតកុំព្យូទ័រនៅក្នុងនាយកដ្ឋានគយ និង ពន្ធដារ ។ នៅក្នុងនាយកដ្ឋានទាំងពីរនេះ ក៏ដូចជានាយកដ្ឋានភាគច្រើនដែរ សមត្ថភាពបំពេញនូវតំរូវការកុំព្យូទ័រនីយកម្ម ទាំងផ្នែករឹង និង ផ្នែកទន់នៅមានកំរិត ឬ មិនមានទាល់តែសោះ ។ ជាលទ្ធផល អនុសាសន៍ដែលតំរូវអោយមានប្រព័ន្ធកុំព្យូទ័រ ប៉ុន្តែមិនបានផ្តល់នូវមូលនិធិ គឺមិនអាចអនុវត្តសំរេចបានទេ ។ ជាឧទាហរណ៍ ប្រព័ន្ធត្រួតពិនិត្យទំនិញដោយប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រដោយជៀសមិនបាន ដើម្បីធ្វើទំនើបនីយកម្ម និងបញ្ច្រាបនីតិវិធីគយ មិនទាន់មានភាគីណាមួយ ទាំងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងម្ចាស់ជំនួយ មិនបានផ្តល់មូលនិធិសំរាប់ទិញទុកសំភារៈនេះនៅឡើយ ។ ដូចនេះហើយ ការដាក់អោយប្រើនូវប្រព័ន្ធដំណើរការត្រួតពិនិត្យគយដោយស្វ័យប្រវត្តិត្រូវបានពន្យារ ហើយភារកិច្ចរបស់ជំនាញការរយៈពេលវែងត្រូវបានពន្យារផងដែរ ។ ច្បាស់ណាស់ដែលថា កង្វះខាតនូវមូលនិធិបង្កើតជាឧបសគ្គក្នុងការជ្រួតជ្រាបជំនួយបច្ចេកទេស ។

៤២-ដូចគ្នាផងដែរ ទីប្រឹក្សាស្ថិតិរយៈពេលវែង បានចំណាយពេលយ៉ាងច្រើន ដើម្បីជួយអាជ្ញាធរក្នុងការរៀបចំអោយមានការផ្តល់មូលនិធិដោយសុវត្ថិភាព ពីសំណាក់ម្ចាស់ជំនួយអន្តរជាតិដើម្បីអនុវត្តនូវការស្ទង់មតិ និង ស្ថិតិតាមអនុសាសន៍ណែនាំ ។ បើគ្មានការផ្តល់ហិរញ្ញវត្ថុពីខាងក្រៅមកទេ ការពង្រីកស្ថិតិសង្គម-សេដ្ឋកិច្ចមិនអាចសំរេចបានឡើយ ។ ជាថ្មីម្តងទៀត កង្វះខាតមូលនិធិសំរាប់អនុវត្តនូវអនុសាសន៍ជំនួយបច្ចេកទេស ជាឧបសគ្គដល់ភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេស ។

៤៣-មិនសំខាន់ថាតើមូលនិធិសំរាប់អនុវត្តអនុសាសន៍ជំនួយបច្ចេកទេស ជាការទទួលខុសត្រូវទាំងស្រុងរបស់អាជ្ញាធររដ្ឋាភិបាល ឬ ក៏មិនមែនទេ បទពិសោធន៍របស់កម្ពុជាបានបង្ហាញថា ដើម្បីបង្កើនការអនុវត្តន៍ ចាំបាច់ត្រូវមានមូលនិធិគ្រប់គ្រាន់ ដោយមិនសំខាន់ថាមូលនិធិនេះមានប្រភពពីណាមកទេដើម្បីអនុវត្តអនុសាសន៍ជំនួយបច្ចេកទេស ។ ការសំរបសំរួលជិតស្និទ្ធក្នុងចំណោមម្ចាស់ជំនួយអន្តរជាតិផ្តល់ជា «កញ្ចប់ធំមួយ» ដែលអនុសាសន៍ជំនួយបច្ចេកទេស អាចផ្សារភ្ជាប់ទៅនឹងធនធានសំរាប់អនុវត្តបានល្អ ។ ការដាក់ចូលគ្នាក្នុងកញ្ចប់តែមួយនូវធនធានម្ចាស់ជំនួយទាំងអស់នឹងធ្វើអោយប្រាកដពីដំបូងថា អនុសាសន៍ជំនួយបច្ចេកទេសមានមូលនិធិគ្រប់គ្រាន់សំរាប់អនុវត្តរហូត

ទទួលបានលទ្ធផលពេញចិត្ត ។ គេត្រូវតែចោទជាសំនួរអំពីហេតុផលនៃការចាប់ផ្តើមអនុវត្តគំរោងជំនួយបច្ចេកទេសដែលអនុសាសន៍តំរូវអោយមានធនធានហិរញ្ញវត្ថុ ប៉ុន្តែលទ្ធភាពធនធានពុំមានលក្ខណៈប្រាកដប្រជា [26]។

## ឃ ការតាមដាននិងត្រួតពិនិត្យនូវវឌ្ឍនភាព កំឡុងពេលអនុវត្តន៍គំរោង

៤៤. ភាពទន់ខ្សោយមួយនៃជំនួយបច្ចេកទេស ដែលគេតែងតែលើកមកនិយាយជាញឹកញាប់ គឺ កង្វះខាតនូវការត្រួតពិនិត្យអោយបានគ្រប់គ្រាន់ ។ ជាពិសេស រាល់ការវាយតំលៃនូវជំនួយបច្ចេកទេសពីមុន រួមទាំងករណីថ្មីៗនេះផងបង្ហាញថា នាយកដ្ឋានទទួលជំនួយបច្ចេកទេសមិនមានប្រព័ន្ធត្រួតពិនិត្យជាប្រចាំទៅលើអនុសាសន៍ ដែលជំនាញការបានផ្តល់ឡើយ [27]។ កង្វះខាតនូវធនធាន បណ្តាលអោយមានភាពខ្វះខាតនូវការតាមដាន និង ត្រួតពិនិត្យ ហើយច្បាស់ណាស់នឹងជះផលជាអវិជ្ជមានចំពោះការអនុវត្តន៍និងប្រសិទ្ធិភាព ។ ជាលទ្ធផល វិធីសាស្រ្តដ៏ទូលំទូលាយមួយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិសំរាប់ការត្រួតពិនិត្យ និង វាយតំលៃត្រូវបានលើកឡើងថា ជាជំហានដ៏ចាំបាច់មួយដើម្បីអោយដឹងថាអនុសាសន៍ណាដែល «ដើរ» ឬ ដំណើរការ ហើយអនុសាសន៍ណាដែល «មិនដើរ» [28] ។

៤៥. ក្នុងន័យនេះ បទពិសោធន៍នៅកម្ពុជាផ្តល់ជាមេរៀនគួរអោយចាប់អារម្មណ៍មួយចំនួន។ ថ្វីបើការត្រួតពិនិត្យភាគច្រើនត្រូវបានធ្វើដោយជំនាញការប្រចាំសំរាប់រយៈពេលវែង ការត្រួតពិនិត្យនេះត្រូវបានធ្វើឡើងដោយ STA ស្តីពីភាពជឿនលឿននៃអនុសាសន៍ជំនួយបច្ចេកទេស ផ្តល់ជាឧទាហរណ៍ មួយថាតើ ធ្វើយ៉ាងណាឱ្យការត្រួតពិនិត្យមានលក្ខណៈជាប្រព័ន្ធអាចដំណើរការបាន ។

៤៦. ក្រសួងដែលមានជំនួយបច្ចេកទេសផ្នែកស្ថិតិ មានធនាគារជាតិកម្ពុជា និង វិទ្យាស្ថានជាតិស្ថិតិ តំរូវអោយផ្ញើររបាយការណ៍ដែលគេបានធ្វើទៅអោយបុគ្គលិក STA នៃមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ដោយមធ្យោបាយនេះ STA មានទិន្នផលដែលអាចវាស់បានមួយ ដែលអនុញ្ញាតអោយគេវាយតំលៃពីភាពជឿនលឿន និង ភាពខ្វះខាត នៃជំនួយបច្ចេកទេស ។ បន្ថែមលើនេះទៀត មន្ត្រីរដ្ឋាភិបាលទទួលស្គាល់ថា ការត្រួតពិនិត្យជាប្រចាំផ្តល់នូវការលើកទឹកចិត្តដ៏ល្អ ។ ការដឹងឮរបស់ពួកគេដែលថា បុគ្គលិក STA កំពង់សង្កេតលើភាពទាន់ពេលវេលា និង គុណភាពនៃការងាររបស់គេ គឺជាការលើកទឹកចិត្តមួយដើម្បីឱ្យពួកគេខំប្រឹងធ្វើការ ។ លទ្ធផលដូចគ្នានឹងទទួលបានចំពោះគំនិតដែលបង្កើតអោយមានជំនាញការដើរបង្រៀន និង ក្រុមបេសកកម្មសំរាប់រយៈពេលខ្លី ។ ទាំងមន្ត្រី និងជំនាញការរយៈពេលវែងបានទទួលស្គាល់ថា ពេលដែលបេសកកម្មថ្មីជិតមកដល់ ផលិតភាពបានកើនឡើង ។ ការ

---

[26] ទាំងនេះលើកជាបញ្ហាថា លុយចំណាយច្រើនពេកទៅលើជំនាញការ ។ លុយជាង ៩០ ភាគរយនៃវិភាគទានហិរញ្ញវត្ថុទាំងអស់ នៅក្រោមកម្មវិធីសហប្រតិបត្តិការជំនួយបច្ចេកទេស ត្រូវបានប្រើប្រាស់លើជំនាញការ ។ អាជ្ញាររដ្ឋាភិបាល តែងតែនិយាយថា គួរ ចំណាយលុយតិចលើជំនាញការ ហើយផ្តល់ហិរញ្ញប្បទានច្រើនដល់ការអនុវត្តន៍អនុសាសន៍ជំនួយបច្ចេកទេស ។

[27] មើល Diamond, Jack និង អ្នកដ៏ទៃកំណែទំរង់ការគ្រប់គ្រងចំណាយសាធារណៈនៅក្នុងបណ្តាប្រទេសអាហ្វ្រិកនិយាយភាសា អង់គ្លេសៈ ការវាយតំលៃនៃជំនួយបច្ចេកទេស ដោយនាយកដ្ឋានកិច្ចការសារពើពន្ធ ខែ កក្កដា (ឆ្នាំ២០០២) ។ និង Chevauchez, Benoit, ការវាយតំលៃជាអន្តរជាតិនៃការគ្រប់គ្រងចំណាយសាធារណៈ លើជំនួយបច្ចេកទេសនៅក្នុងបណ្តាប្រទេសអាហ្វ្រិកនិយាយភាសាបារាំងរបស់នាយកដ្ឋានកិច្ចការសារពើពន្ធ ឆ្នាំ (២០០៣) ។

[28] មើលសេចក្តីប្រកាសព័ត៌មានសាធារណៈ លេខ ០២/៧៣ ការពិនិត្យឡើងវិញនូវគោលនយោបាយជំនួយបច្ចេកទេស និង បទពិសោធន៍ ឆ្នាំ ២០០២ ។

ពិនិត្យដិតដល់បានបង្កើតការលើកទឹកចិត្តដល់មន្ត្រីរដ្ឋាភិបាល ក្នុងន័យមួយ ដែលបង្កើននូវភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេស ។

៤៧. នៅក្នុងពិភពលោកដ៏សុក្រិត្យមួយ មូលនិធិរូបិយវត្ថុអន្តរជាតិ អាចមានលទ្ធភាពបង្កើតបាននូវប្រព័ន្ធមួយដែលអាចត្រួតពិនិត្យពីភាពជឿនលឿននៃជំនួយបច្ចេកទេស តាមរបៀបដូចគ្នាទៅនឹងវិធីដែល STA ត្រួតពិនិត្យការងារនៃមន្ត្រីស្ថិតិ ។ ថ្វីបើមានភាពប្រាកដប្រជាថា ទិន្នផលត្រួតពិនិត្យរបស់ STA មានលក្ខណៈសាមញ្ញជាងដោយគិតទៅដល់ប្រភេទនៃលទ្ធផលដែលត្រូវបានរំពឹងទុកពីប្រភេទនៃជំនួយបច្ចេកទេស ការខំប្រឹងប្រែងទូទៅមួយដើម្បីបង្កើតការត្រួតពិនិត្យជាប្រព័ន្ធ និង ផ្តល់មូលនិធិអោយបានទូលំទូលាយ គឺជាប្រការប្រសើរបំផុត ។

## ៥. សេចក្តីសន្និដ្ឋាន

៤៨-កិច្ចប្រឹងប្រែងផ្តល់ជំនួយបច្ចេកទេសនៅកម្ពុជាមានលទ្ធផលផ្សេងៗគ្នា ។ កំណែទំរង់វិស័យធនាគារ និង កំណែទំរង់ស្ថិតិសេដ្ឋកិច្ច អាចចាត់ទុកថាជាជោគជ័យមួយ ផ្ទុយទៅវិញជំនួយបច្ចេកទេសលើវិស័យសារពើពន្ធជួបប្រទះបញ្ហាលំបាកច្រើន ។ ដូចបានលើកឡើងក្នុងកថាខ័ណ្ឌមុនៗ មានកត្តាជាច្រើនជះឥទ្ធិពល នឹងធ្វើអោយមានលទ្ធផលខុសៗគ្នាបែបនេះ ដែលផ្តល់ឱ្យមេរៀនយ៉ាងសំខាន់ដល់ការផ្តល់ជំនួយបច្ចេកទេសលើកក្រោយៗទៀត ។

- **ឆន្ទៈនយោបាយ** ជាលក្ខខ័ណ្ឌចាំបាច់បំផុតដើម្បីអោយជំនួយបច្ចេកទេសទទួលជោគជ័យ ។ បើគ្មានវាទេនោះកិច្ចប្រឹងប្រែងណាមួយនឹងបរាជ័យ ។ នេះគឺជាមូលហេតុចាំបាច់ដើម្បីត្រួតពិនិត្យអោយដិតដល់ ចំពោះឆន្ទៈរបស់អាជ្ញាធរ ក្នុងករណីកង្វះភាពច្បាស់លាស់ និងតម្លាភាព ។ ម៉្យាងទៀត មូលនិធិរូបិយវត្ថុអន្តរជាតិគួរប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ក្នុងករណីពុំមានការប្តេជ្ញាច្បាស់លាស់ក្នុងការអនុវត្តន៍តាមអនុសាសន៍ ។
- **មុខងារសាធារណៈមួយមានដំណើរការ** គឺ ជាបុរេល័ក្ខខ័ណ្ឌមួយទៀតក្នុងការធ្វើអោយមានការជ្រួតជ្រាបនូវជំនួយបច្ចេកទេស ដែលអាចយកជាការបាន និង យូរអង្វែង ។ បើសិនជាមន្ត្រីរាជការមិនមានជីវិតបៀវត្សអប្បបរមាប្រកបដោយស្ថិរភាព និង ប្រកួតប្រជែង ភាពជ្រួតជ្រាបនៃជំនួយបច្ចេកទេសនឹងត្រូវខូចខាតដោយអត្រាលះបង់/ផ្ទេរការងារមានកំរិតខ្ពស់ ហើយការផ្ទេរចំណេះដឹងមានលក្ខណៈយឺតយ៉ាវ ។
- កែលំអ **ការសំរបសំរួលរវាងម្ចាស់ជំនួយ** ជាភាពចាំបាច់មិនត្រឹមតែដើម្បីជួយសំរួលអភិក្រមមានចរិកជាប្រព័ន្ធប៉ុណ្ណោះទេ តែថែមទាំងដើម្បីជៀសវាងនូវអនុសាសន៍ដែលផ្ទុយគ្នា អំពែកផ្ទែករដ្ឋបាលហួសហេតុ និង លេសចំពោះករណីមិនទទួលបានលទ្ធផល ។
- **បេសកកម្មវិនិច្ឆ័យមានរយៈពេលវែង ឬ ក្នុងកំរិតអប្បបរមាមួយ** ទំនងមានភាពសមស្របនៅប្រទេស ដូចជាកម្ពុជា ជាពិសេសចំពោះវិស័យទាំងឡាយណាដែលមានភាពប្រែប្រួលយ៉ាងខ្លាំងរវាងប្រទេសនីមួយៗ ។ នេះគឺជាបញ្ហា ព្រោះថាបេសកកម្មរយៈពេលខ្លី មិនអាចមានពេលគ្រប់គ្រាន់ដើម្បីស្វែងយល់បានទាំងស្រុងពីលក្ខណៈពិសេសរបស់ស្ថាប័ន នៅក្នុងប្រទេសនីមួយៗបានទេ ។
- វាជាប្រការប្រសើរមួយ ដែលត្រូវបញ្ជាក់ច្បាស់ថា **មន្ត្រី** ជាពិសេសអ្នកទទួលបន្ទុកអនុវត្ត ត្រូវបាន**ផ្តល់ពត៌មានច្បាស់លាស់ជាមុន** អំពីហេតុផលពាក់ព័ន្ធនឹងអនុសាសន៍ស្នើឡើងដើម្បីពង្រឹងភាពជាម្ចាស់ការ ។ រឿងនេះ ជាប្រការប្រឈមមួយ និង មានសារៈសំខាន់ នៅក្នុងបរិបទដែលទំនាក់ទំនងរវាងបណ្តាក្រសួង និងផ្នែកក្នុងក្រសួង មិនរលូនគ្រប់គ្រាន់ ។

- ដើម្បីជៀសវាងកុំអោយប្រទេសទាំងឡាយ **«ញៀន»** នឹងជំនួយបច្ចេកទេស ចាំបាច់ណាស់ត្រូវគ្រោងផែនការ **ដកចេញនូវជំនួយបច្ចេកទេស** ដើម្បីលើកទឹកចិត្តដល់អាជ្ញាធរឱ្យចាប់ផ្តើមដើរដោយខ្លួនឯង និង ជួយគេអោយ «ឈានឡើង» ។ លទ្ធភាពមួយគឺ ការប្តូរពីជំនាញការរយៈពេលវែងមកជាជំនាញការរយៈពេលខ្លីៗ ក្នុងខណៈដែលសមត្ថភាពត្រូវបានកសាងប្រកបដោយជោគជ័យ ហើយហួសពីកំរិតជាក់លាក់ណាមួយ ។
- បទពិសោធន៍នៅកម្ពុជាបង្ហាញថាជំនាញការរយៈពេលវែងល្អបំផុត គួរតែជាជំនាញការមាន**បទពិសោធន៍ការងារជាក់ស្តែងខ្ពស់** មាន**ជំនាញផ្នែកគ្រប់គ្រង និង បទពិសោធន៍ការងារការិយាល័យ ។**
- ការសម្របសម្រួលជិតស្និទ្ធជាមួយម្ចាស់ជំនួយអន្តរជាតិ ដើម្បីធានាអោយបានជា «កញ្ចប់ពេញលេញ» ដែលអនុសាសន៍ជំនួយបច្ចេកទេស ត្រូវស៊ីគ្នានឹងធនធានរបស់ម្ចាស់ជំនួយទាំងនោះ គឺជាប្រការប្រសើរបំផុត ។ **ការដាក់ចូលជាកញ្ចប់តែមួយនូវធនធានជំនួយ** ដើម្បីអោយមានការជឿជាក់ជាមុនថា រាល់អនុសាសន៍ស្នើឡើងដោយជំនួយបច្ចេកទេស នឹងមានមូលនិធិគ្រប់គ្រាន់សំរាប់គាំទ្រ គឺជារឿងប្រពៃមួយទៀត ។
- ជាប្រការល្អប្រសើរក្នុងការបង្កើតប្រព័ន្ធមួយ ដែលអាចត្រួតពិនិត្យពីភាពជឿនលឿននៃជំនួយបច្ចេកទេសជាប្រចាំ និង អោយបានជិតដល់ ។ បទពិសោធន៍នៅកម្ពុជាបង្ហាញថា ការត្រួតពិនិត្យជិតដល់ធ្វើអោយមានការអនុវត្តន៍ល្អ និង មន្ត្រីរដ្ឋបាលធ្វើការមានផលិតភាពខ្ពស់ ។
- **កម្មវិធីកិច្ចសហប្រតិបត្តិការជំនួយបច្ចេកទេស** ត្រូវទទួលស្គាល់ដោយម្ចាស់ជំនួយបច្ចេកទេសទាំងអស់ថាជាការស្ថាបនាដំណាក់កាលមួយដ៏មានតម្លៃ សំរាប់អនុវត្តនូវក្របខ័ណ្ឌរយៈពេលមធ្យមមួយ ក្នុងការផ្តល់ជំនួយបច្ចេកទេស ជាមួយគ្នានេះ វាជាយន្តការដំបូងមួយដើម្បីសម្របសម្រួលក្នុងចំណោមម្ចាស់ជំនួយ ។ ទោះបីយ៉ាងនេះក្តី កម្មវិធីកិច្ចសហប្រតិបត្តិការជំនួយបច្ចេកទេសភាគច្រើនកើតឡើងពីគំនិតផ្តួចផ្តើមដាច់ៗពីគ្នា ដែលមិនអាចប្រមូលផ្តុំធ្វើជាយុទ្ធសាស្ត្រមួយសំរាប់ការកសាងសមត្ថភាព ហើយការអនុវត្តន៍នៃសមាសធាតុនីមួយៗទៀតសោត ស្ថិតក្នុងសភាពដាច់ដោយឡែកៗពីគ្នានៅឡើយ ។ ជាលទ្ធផល ការដោះស្រាយកង្វះខាតសមត្ថភាពតែងតែត្រូវបានធ្វើឡើងតាមរបៀបមួយម្តងៗ ដោយគ្មានការសម្របសម្រួលអោយបានទូលំទូលាយរវាងម្ចាស់ជំនួយនៅឡើយ ។

# ឧបសម្ព័ន្ធ ១

បញ្ជីឈ្មោះអ្នកត្រូវបានសម្ភាសន៍

| ឈ្មោះ | តួនាទី | ស្ថាប័ន |
|---|---|---|
| Mr. Shyam P. Bajpai | ប្រធានទទួលបន្ទុកប្រចាំប្រទេស | ធនាគារអភិវឌ្ឍន៍អាស៊ី |
| Mr. Purnima Rajapakse | សេដ្ឋកិច្ចវិទូជាន់ខ្ពស់ផ្នែកកម្មវិធី | ធនាគារអភិវឌ្ឍន៍អាស៊ី |
| លោក វ៉ាន់ឌី ហែម | មន្ត្រីផ្នែកហិរញ្ញវត្ថុ និង សេដ្ឋកិច្ច | ធនាគារអភិវឌ្ឍន៍អាស៊ី |
| លោក ចំរើន អ៊ុច | មន្ត្រីទទួលបន្ទុកកម្មវិធី | ធនាគារអភិវឌ្ឍន៍អាស៊ី |
| Dr. Daniel Arghiros | ប្រធានការិយាល័យនិងទីប្រឹក្សាខាងអភិបាលកិច្ច | ក្រសួងសំរាប់អភិវឌ្ឍអន្តរជាតិ |
| Mr. Brian Thornton | ទីប្រឹក្សាផ្នែកប្រព័ន្ធថវិកានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| Mr. Patrick Huges | ទីប្រឹក្សានៃធនាគារជាតិកម្ពុជា | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| Mr. Bruce G. Hill | ទីប្រឹក្សានៃនាយកដ្ឋានគយ និង ពន្ធដារ | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| Mr. Colin Nagle | ទីប្រឹក្សាស្ថិតិពហុវិស័យ | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| Mr. Robert Hagemann | ស្ថានតំណាង | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| Mr. Patricio Castro | សេដ្ឋកិច្ចវិទូជាន់ខ្ពស់ | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| Mr. Il Houng Lee | អនុប្រធានផ្នែក | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| Mr. Mario de Zamaroczy | ទីប្រឹក្សា | មូលនិធិរូបិយវត្ថុអន្តរជាតិ |
| លោក ហុង ថា | ប្រធាននាយកដ្ឋានពន្ធដារ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| លោក អ៊ុំ សីហា | អនុប្រធាននាយកដ្ឋានពន្ធដារ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| លោក គុណ ញឹម | អនុប្រធាននាយកដ្ឋានទីចាត់ការគយនិងរដ្ឋាករ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| លោក អូន ព័ន្ធមុនីរ័ត្ន | រដ្ឋលេខាធិការ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| លោក អៀង ស៊ុនលី | អនុប្រធានទី១នៃនាយកដ្ឋានថវិកានិងកិច្ចការហិរញ្ញវត្ថុ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| លោក សុខ សារាវុឌ្ឍ | អនុប្រធានអង្គភាពគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |
| លោក ហង់ ជួន ណារ៉ុន | អគ្គលេខាធិការរង | ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ |

| | | |
|---|---|---|
| លោក ខៃ ពូស្មិទ្ធ | ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច | ធនាគារជាតិកម្ពុជា |
| អ្នកស្រី តាល់ ណៃអ៊ឹម | អគ្គលេខាធិការ | ធនាគារជាតិកម្ពុជា |
| លោក ផាន ហូ | ប្រធាននាយកដ្ឋានត្រួតពិនិត្យធនាគារ | ធនាគារជាតិកម្ពុជា |
| អ្នកស្រី នាវ ចាន់តានា | អនុប្រធាននាយកដ្ឋានត្រួតពិនិត្យធនាគារ | ធនាគារជាតិកម្ពុជា |
| លោក សុខាំ តាន់ | ត្រួតពិនិត្យធនាគារ | ធនាគារជាតិកម្ពុជា |
| លោក វ័ត្ត សារុឌ | ប្រធាននាយកដ្ឋានប្រតិបត្តការធនាគារ | ធនាគារជាតិកម្ពុជា |
| លោក កែម គុណថា | អនុប្រធាននាយកដ្ឋានធនាគារ | ធនាគារជាតិកម្ពុជា |
| លោក ហ៊ុយ ណារី | ប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | ធនាគារជាតិកម្ពុជា |
| កញ្ញា សុខាន់ តាន់ | អនុប្រធាននាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ | ធនាគារជាតិកម្ពុជា |
| លោក សាន ស៊ីថន | ប្រធាននាយកដ្ឋាននៃវិទ្យាស្ថានជាតិស្ថិតិ | វិទ្យាស្ថានជាតិស្ថិតិ |
| Mr. Ladislaus Byenkya-Abwooli | អនុប្រធានស្ថានតំណាង | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| Ms. Ingrid Cyimana | ប្រធានក្រុមផ្នែកកាត់បន្ថយភាពក្រីក្រ | កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ |
| Mrs. Nisha Agrawal | ប្រធានធនាគារពិភពលោកប្រចាំកម្ពុជា | ធនាគារពិភពលោក |

## ឯកសារយោង

Chevauchez, Benoit, ការវាយតំលៃជាអន្តរជាតិនៃការគ្រប់គ្រងចំណាយសាធារណៈលើជំនួយបច្ចេកទេសនៅក្នុងបណ្តាប្រទេសអាហ្វ្រិកនិយាយភាសាបារាំងរបស់នាយកដ្ឋានកិច្ចការសារពើពន្ធ ឆ្នាំ ២០០៣ ។

De Zamarozcy and Sa, គោលនយោបាយសេដ្ឋកិច្ចនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកយ៉ាងខ្លាំងលើប្រាក់ដុល្លា OP219, មូលនិធិរូបិយវត្ថុអន្តជាតិ ឆ្នាំ ២០០៣។

Diamond, Jack និង អ្នកដទៃទៀតណែទំរង់ការគ្រប់គ្រងចំណាយសាធារណៈនៅក្នុងបណ្តាប្រទេសអាហ្វ្រិក និយាយភាសាអង់គ្លេសៈ ការវាយតំលៃជំនួយនៃជំនួយបច្ចេកទេស FAD, ដោយនាយកដ្ឋានកិច្ចការសារពើពន្ធ ខែ កក្កដា ឆ្នាំ២០០២ ។

Evans Peter, Rauch James," រចនាសម្ព័ន្ធ និង ដំណើរការនៃការិយាល័យនៅក្នុងប្រទេស ដែលអភិវឌ្ឍន៍តិចតួចបំផុត » នៅក្នុងទស្សនាវដ្តីសេដ្ឋកិច្ចសាធារណៈ លេខ៧៥ ទំព័រ ៤៩-៦២ ខែ មករា ឆ្នាំ ២០០០ ។

Frydl, Edward, Juan Foxley, and Eddie Herron, វិស័យធនាគារ បញ្ហាគណនេយ្យ និង ការគ្រប់គ្រងទុនបំរុងរូបិយប័ណ្ណបរទេស ខែ ធ្នូ ឆ្នាំ២០០៣ ។

រាជរដ្ឋាភិបាលកម្ពុជា ប្រទេសកម្ពុជា : កម្មវិធីជំនួយសហប្រតិបត្តិការ បច្ចេកទេសថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០១។

រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍ពីភាពជឿនលឿននៃកម្មវិធីជំនួយសហប្រតិបត្តិការបច្ចេកទេស ខែ មេសា ឆ្នាំ ២០០៣ ។

មូលនិធិរូបិយវត្ថុអន្តរជាតិ ប្រទេសកម្ពុជា មាត្រា ៤ ឆ្នាំ ២០០០ ។

មូលនិធិរូបិយវត្ថុអន្តរជាតិ ការពិនិត្យឡើងវិញនៃបទពិសោធន៍ និង គោលនយោបាយនៃជំនួយបច្ចេកទេស ដោយការិយាល័យគ្រប់គ្រងជំនួយបច្ចេកទេស ឆ្នាំ ២០០០ ។

មូលនិធិរូបិយវត្ថុអន្តរជាតិ ប្រទេសកម្ពុជា មាត្រា ៤ ឆ្នាំ ២០០២ ។

មូលនិធិរូបិយវត្ថុអន្តរជាតិ ប្រទេសកម្ពុជា : សេចក្តីសង្ខេបនៃយុទ្ធសាស្ត្រសារពើពន្ធ ដោយនាយកដ្ឋានកិច្ចការសារពើពន្ធ ឆ្នាំ ២០០៣ ។

មូលនិធិរូបិយវត្ថុអន្តរជាតិ ប្រទេសកម្ពុជាៈ សេចក្តីសង្ខេបនៃយុទ្ធសាស្ត្រសារពើពន្ធ ដោយនាយកដ្ឋានកិច្ចការសារពើពន្ធ ឆ្នាំ ២០០៤។

មូលនិធិរូបិយវត្ថុអន្តរជាតិ ប្រទេសកម្ពុជា ការវាយតំលៃតាមក្រោយនៃកិច្ចសន្យាកម្មវិធីសំរាប់រយៈពេលវែង ឆ្នាំ ២០០៤ ។

មូលនិធិរូបិយវត្ថុអន្តរជាតិ ការពិនិត្យឡើងវិញនៃកម្មវិធីវាយតំលៃជំនួយបច្ចេកទេស និង លទ្ធផលនៃការវាយតំលៃ និងកម្មវិធីថ្មីៗ ដោយការិយាល័យគ្រប់គ្រងជំនួយបច្ចេកទេស ឆ្នាំ ២០០៤ ។

Prakash, Tej., et. al., កម្ពុជាៈ ក្របខ័ណ្ឌសំរាប់ការកែលំអ ការគ្រប់គ្រងចំណាយ មូលនិធិរូបិយវត្ថុអន្តរជាតិ កញ្ញា ឆ្នាំ ២០០១។

សន្និសីទសហប្រជាជាតិអំពីពាណិជ្ជកម្ម និង ការអភិវឌ្ឍន៍ (UNCTAD) របាយការណ៍វាយតំលៃលើកម្មវិធីជំនួយសហប្រតិបត្តិការបច្ចេកទេស (TCAP) ស្តីពីការពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ ២០០៤ ។

កម្មវិធីអភិវឌ្ឍសហប្រជាជាតិ កម្មវិធីនៃរដ្ឋាភិបាលកម្ពុជា : ឯកសារគាំទ្រកម្មវិធី ខែ ឧសភា ឆ្នាំ ២០០១ ។